តារាង 1-3-11 ស្ថានភាពសុខភាព និងអនាម័យ ក្នុងតំបន់គម្រោង ........ 1-18
តារាង 1-3-12 ច្បាប់ និងបញ្ញត្តិបរិស្ថាន កម្ពុជា ........ 1-20
តារាង 1-3-13 ស្តង់ដារបរិស្ថាន ........ 1-21
តារាង 1-3-14 កម្រិតសំឡេងអនុញ្ញាតអតិបរិមា dB(A) ........ 1-21
តារាង 1-3-15 គម្លាតរវាងគោលការណ៍បរិស្ថានកម្ពុជា និង JICA ........ 1-23
តារាង 1-3-16 ការប្រៀបធៀបជម្រើស ........ 1-32
តារាង 1-3-17 លទ្ធផលកំណត់ទំហំគម្រោង ........ 1-33
តារាង 1-3-18 លក្ខខណ្ឌយោង ........ 1-37
តារាង 1-3-19 លទ្ធផលសិក្សាបរិស្ថាន និងសង្គម ........ 1-39

តារាង 1-3-20 សង្ខេបអំពីកិច្ចប្រជុំរវាងអ្នកពាក់ព័ន្ធ ........ 1-45
តារាង 1-3-21 ការវាយតម្លៃផលប៉ះពាល់ ........ 1-47
តារាង 1-3-22 ផលប៉ះពាល់ និងវិធានការកាត់បន្ថយ (វគ្គសាងសង់) ........ 1-50
តារាង 1-3-23 ផលប៉ះពាល់ និងវិធានការកាត់បន្ថយ (វគ្គដំណើរការ) ........ 1-51
តារាង 1-3-24 ដីចាំបាច់សម្រាប់គម្រោង ........ 1-53
តារាង 1-3-25 ផែនការតាមដាន (បណ្តោះអាសន្ន) ........ 1-54
តារាង 1-3-26 ទម្រង់តាមដាន (ពេលសាងសង់) ........ 1-56
Table 1-3-27 បញ្ជីត្រួតពិនិត្យបរិស្ថាន ........ 1-59
តារាង 1-4-1 ភារកិច្ច និងចំនួនបុគ្គលិក ........ 1-65
តារាង 1-4-2 បរិមាណទឹកភ្លៀងប្រចាំខែ និងប្រចាំឆ្នាំ នៅពោធិ៍សាត់ ........ 1-70
តារាង 1-4-3 ប្រព័ន្ធប្រើប្រាស់ទឹកតាមបណ្តោយស្ទឹងពោធិ៍សាត់ (មានស្រាប់ និងគម្រោងអនាគត) ........ 1-71
តារាង 1-4-4 សេចក្តីសង្ខេបអំពីប្រព័ន្ធរោងចក្រប្រព្រឹត្តិកម្មទឹកបច្ចុប្បន្ន ........ 1-83
តារាង 2-1-1 សមាសភាគសំខាន់ៗ នៃគម្រោង ........ 2-3
តារាង 2-2-1 អត្រាភ្លៀងធ្លាក់ប្រចាំខែនៅពោធិ៍សាត់ (1996 – 2015) ........ 2-6
តារាង 2-2-2 ស្ថានភាពបច្ចុប្បន្ននៃការផ្គត់ផ្គង់ទឹកស្អាតនៅពោធិ៍សាត់ (2018) ........ 2-12
តារាង 2-2-3 ចំនួនប្រជាជនក្នុងខេត្តពោធិ៍សាត់ ........ 2-14
តារាង 2-2-4 ចំនួនប្រជាជនក្នុងតំបន់គ្រប់គ្រងដោយរដ្ឋាករទឹកពោធិ៍សាត់ (ថ្នាក់ភូមិ) ........ 2-15
តារាង 2-2-5 ចំនួនប្រជាជនអនាគតក្នុងតំបន់ផ្គត់ផ្គង់ទឹកស្អាត ........ 2-17
តារាង 2-2-6 ប្រជាជនទទួលការផ្គត់ផ្គង់ទឹកស្អាតអនាគត ........ 2-18
តារាង 2-2-7 អត្រាទទួលសេវាទឹកស្អាត ក្នុងតំបន់គ្រប់គ្រង និងក្នុងតំបន់ផ្គត់ផ្គង់ ........ 2-19
តារាង 2-2-8 បរិមាណទឹកប្រើប្រាស់ជាមធ្យមក្នុងម្នាក់ក្នុងមួយថ្ងៃចំពោះលំនៅដ្ឋាន ........ 2-20
តារាង 2-2-9 បរិមាណទឹកប្រើប្រាស់បែងចែកតាមប្រភេទប្រើប្រាស ........ 2-21
តារាង 2-2-10 ទិន្នន័យអត្រាបន្ទុក អតីតកាល ........ 2-22
តារាង 2-2-11 បរិមាណតម្រូវការទឹកនាពេលអនាគត ........ 2-24
តារាង 2-2-12 លក្ខណៈបច្ចេកទេសសំខាន់ៗក្នុងគម្រោង (I) ........ 2-25
តារាង 2-2-13 លក្ខណៈបច្ចេកទេសសំខាន់ៗក្នុងគម្រោង (II) ........ 2-26
តារាង 2-2-14 ការប្រៀបធៀបវិធីសាស្ត្របូមទឹកឆៅ ........ 2-32
តារាង 2-2-15 ការជ្រើសរើសប្រភេទស្ថានីយបូមទឹកបណ្តែត ........ 2-34
តារាង 2-2-16 អង្កត់ផ្ចិតអាងពង្រងខ្សាច់ ........ 2-38
តារាង 2-2-17 ល្បឿននៃការរងរបស់ខ្សាច់ ........ 2-38
តារាង 2-2-18 លក្ខណៈបច្ចេកទេសអាងពង្រង (2 អាង) ........ 2-40
តារាង 2-2-19 លក្ខណៈបច្ចេកទេសអាងប្រភេទទឹកក្បួច ........ 2-42
តារាង 2-2-20 លក្ខណៈបច្ចេកទេសអាងប្រភេទទឹកក្បួច ........ 2-43
តារាង 2-2-21 ការប្រៀបធៀបប្រភេទអាងពង្រង ........ 2-50

តារាង 2-2-22 កម្ពស់សម្ពាធបូម ........ 2-54
តារាង 2-2-23 តារាងបច្ចេកទេសនៃម៉ាស៊ីនបូមទឹកឆៅ ........ 2-55
តារាង 2-2-24 លក្ខណៈបច្ចេកទេសនៃស្ថានីយបូមទឹកឆៅ ........ 2-56
តារាង 2-2-25 ផែនការដាក់បំពង់នាំទឹកឆៅ ........ 2-61
តារាង 2-2-26 ការប្រៀបធៀបវិធីសាស្ត្រកូរសារធាតុគីមី ........ 2-63
តារាង 2-2-27 ការប្រៀបធៀបវិធីដំណើរការផ្គុំកករ ........ 2-65
តារាង 2-2-28 ការប្រៀបធៀបប្រភេទអាងពង្រង ........ 2-66
តារាង 2-2-29 ការប្រៀបធៀបវិធីសាស្ត្រគ្រប់គ្រងធារទឹក ........ 2-68
តារាង 2-2-30 បុរេលក្ខខណ្ឌចាំបាច់សម្រាប់រចនាអាងច្រោះ ........ 2-69
តារាង 2-2-31 លក្ខណៈបច្ចេកទេសជាមូលដ្ឋាននៃអាងច្រោះ ........ 2-70
តារាង 2-2-32 លក្ខណៈបច្ចេកទេសសម្រាប់រោងចក្រប្រព្រឹត្តកម្មទឹកថ្មី ........ 2-75
តារាង 2-2-33 ការប្រៀបធៀបប្រភេទការចែកចាយទឹក ........ 2-80
តារាង 2-2-34 វិធីសាស្ត្រដំឡើងបំពង់នៅតាមចំនុចឆ្លងកាត់នីមួយៗ ........ 2-85
តារាង 2-2-35 លក្ខខណ្ឌរចនាបណ្តាញចែកចាយទឹក ........ 2-87
តារាង 2-2-36 លក្ខណៈបច្ចេកទេសនៃប្រព័ន្ធចែកចាយទឹកស្អាត ........ 2-89
តារាង 2-2-37 សំណើដើមរបស់ភាគីកម្ពុជា និងលទ្ធផលសិក្សា ........ 2-91
តារាង 2-2-38 ឧបករណ៍វាស់គុណភាពទឹកក្នុងរោងចក្រប្រព្រឹត្តកម្មទឹកដែលមានស្រាប់ ........ 2-92
តារាង 2-2-39 សង្ខេបអំពីឧបករណ៍ដែលត្រូវផ្តល់ ........ 2-94
តារាង 2-2-40 បញ្ជីរប្លង់រចនា ........ 2-95
តារាង 2-2-41 ការងារសំខាន់ៗ និងវិធីសាស្ត្រត្រួតពិនិត្យគុណភាព ........ 2-103
តារាង 2-2-42 តួនាទី និងទំនួលខុសត្រូវ ........ 2-107
តារាង 2-2-43 ការប្រឈម និងស្ថានភាពបច្ចុប្បន្ន ........ 2-108
តារាង 2-2-44 សកម្មភាពបណ្តុះបណ្តាល (Input Plan) ........ 2-110
តារាង 2-3-1 កាតព្វកិច្ចនៃភាគីម្ចាស់គម្រោង (មុនការដេញថ្លៃ) ........ 2-114
តារាង 2-3-2 កាតព្វកិច្ចភាគីម្ចាស់គម្រោង (កំឡុងពេលអនុវត្តគម្រោង) ........ 2-115
តារាង 2-3-3 កាតព្វកិច្ចរបស់ម្ចាស់គម្រោង (បន្ទាប់ពីគម្រោង) ........ 2-116
តារាង 2-3-4 ទីតាំងស្តុកសម្ភារៈបណ្តោះអាសន្ន និងទីតាំងចាក់ដីចោល ........ 2-121
តារាង 2-4-1 រចនាសម្ព័ន្ធដំណើរការប្រព័ន្ធ ត្រឹម ២០២៥ ........ 2-122
តារាង 2-4-2 វេនការងារដំណើរការ និងថែទាំប្រព័ន្ធប្រព្រឹត្តិកម្មថ្មី ........ 2-123
តារាង 2-4-3 ផែនការដំឡើងចំនួនបុគ្គលិក ........ 2-125
តារាង 2-4-4 ចំនុចថែទាំ ........ 2-126
តារាង 2-5-1 តម្លៃគម្រោងរ៉ាប់រងដោយភាគីកម្ពុជា ........ 2-128
តារាង 2-5-2 តម្លៃពលកម្ម (USD※1) ........ 2-129
តារាង 2-5-3 សង្ខេបរបាយការណ៍ចំណេញខាតរបស់អង្គភាពរដ្ឋាករទឹកពោធិ៍សាត់ ........ 2-130
តារាង 2-5-4 សេចក្តីសង្ខេបអំពីរបាយការណ៍សមតុល្យរបស់អង្គភាពរដ្ឋាករទឹកពោធិ៍សាត់ ........ 2-132

តារាង 2-5-5 អត្រានៃទ្រព្យម្ចាស់ធៀបនឹងទ្រព្យសកម្មសរុបរបស់អង្គភាពរដ្ឋាករទឹកពោធិ៍សាត់ ........................................ 2-132
តារាង 2-5-6 បំណុលសរុបរដ្ឋាភិបាល (ភាគរយនៃ GDP) ........................................ 2-133
តារាង 2-5-7 ផលធៀបសកម្ម របស់អង្គភាពរដ្ឋាករទឹកពោធិ៍សាត់ ........................................ 2-134
តារាង 2-5-8 សមាសភាពនៃទឹកលក់បានតាមប្រភេទអតិថិជន ........................................ 2-134
តារាង 2-5-9 ចំណូលពីការលក់ទឹក ........................................ 2-135
តារាង 2-5-10 បរិមាណទឹកចែកចាយ និងទឹកលក់បាន ........................................ 2-135
តារាង 2-5-11 បរិមាណទឹកចែកចាយ និងទឹកលក់បានរបស់ប្រព័ន្ធដែលមានស្រាប់ (ព្យាករណ៍) ........................................ 2-137
តារាង 2-5-12 បិរមាណទឹកចែកចាយ និងលក់បានដោយប្រព័ន្ធពង្រីកថ្មី (ព្យាករណ៍) ........................................ 2-137
តារាង 2-5-13 បិរមាណទឹកចែកចាយ និងលក់បានសរុប (ព្យាករណ៍) ........................................ 2-137
តារាង 2-5-14 តម្លៃឯកតាប៉ាន់ស្មានសម្រាប់ដំណើរការ និងការថែទាំ ........................................ 2-138
តារាង 2-5-15 ចំនួនបុគ្គលិកក្នុងរចនាសម្ព័ន្ធបច្ចុប្បន្ន ........................................ 2-138
តារាង 2-5-16 ផែនការបុគ្គលិក ........................................ 2-139
តារាង 2-5-17 ការព្យាករណ៍រយៈពេលវែងនៃការចំណេញខាត ........................................ 2-140
តារាង 3-4-1 លទ្ធផលជាបរិមាណ ........................................ 3-4

# ពាក្យកាត់

| | |
|---|---|
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី |
| ADCP | ឧបករណ៍វាស់ចរន្តទឹក ADCP (Acoustic Doppler Current Profiler) |
| AFD | ទីភ្នាក់ងារបារាំងដើម្បីការអភិវឌ្ឍន៍ |
| APGR | អត្រាកំណើនប្រជាជនប្រចាំឆ្នាំ |
| ARAP | ផែនការសកម្មភាពផ្លាស់ទីលំនៅសង្ខេប (Abbreviated Resettlement Action Plan) |
| BM | ចំនុចតម្រុយ |
| CDC | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| CMAC | មជ្ឈមណ្ឌលកំចាត់មីនកម្ពុជា |
| CMDGs | គោលដៅអភិវឌ្ឍន៍សហសវត្សកម្ពុជា |
| CRC | គណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ា |
| DAIS | ប្រព័ន្ធស្រោចស្រពដំណាក់អំពិល |
| DCIS | ប្រព័ន្ធស្រោចស្រពដំណាក់ឈើក្រំ |
| DIH | មន្ទីរឧស្សាហកម្ម និងសិប្បកម្ម |
| DIP (DCIP) | បំពង់ DCIP |
| DOA | មន្ទីរកសិកម្ម |
| DORWAM | មន្ទីរធនធានទឹក និងឧត្តុនិយម |
| DOE | មន្ទីរបរិស្ថាន |
| DPWS | នាយកដ្ឋានទឹកស្អាត |
| DPWT | មន្ទីរសាធារណការ និងដឹកជញ្ជូន |
| EAC | អាជ្ញាធរអគ្គិសនីកម្ពុជា |
| EC | គណៈកម្មាធិការអស្សាមីករណ៍ |
| EDC | អគ្គិសនីកម្ពុជា |
| EIA | ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន |
| EL | រយៈកម្ពស់ (ធៀបទឹកសមុទ្រ) |
| FS (F/S) | ការសិក្សាសមិទ្ធិលទ្ធភាព |
| GOC | រាជាណាចក្រកម្ពុជា |
| GOJ | រដ្ឋាភិបាលជប៉ុន |
| GRET | Groupe de Recherche et d'Échanges Technologiques |
| HDPE | ប៉ូលីអេទីឡែនដែលមានដង់ស៊ីតេខ្ពស់ |
| HW | ទំនប់ស្រោចស្រព (Headworks) |
| HWL | នីវ៉ូទឹកខ្ពស់ |
| IBA | តំបន់បក្សីសំខាន់ |
| IEC | គណៈកម្មការបច្ចេកទេសអេឡិចត្រូនិចអន្តរជាតិ |
| IEE | ការសិក្សាបរិស្ថានដំបូង |
| IEIA | ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង |
| IMO | អង្គភាពតាមដានឯករាជ្យ |
| IRC | ដំណើរការផ្លាស់ទីលំនៅអន្តរក្រសួង |
| ISO | អង្គការស្តង់ដារអន្តរជាតិ |
| IWRM | សមាហរ័ណកម្មគ្រប់គ្រងធនធានទឹក |
| JEC | គណៈកម្មាធិការបច្ចេកទេសអេឡិចត្រូនិចជប៉ុន |
| JICA | ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន |
| JIS | ស្តង់ដារឧស្សាហកម្មជប៉ុន |
| KBA | តំបន់ជីវចម្រុះសំខាន់ |
| KHR | លុយរៀល |
| LCC | Life-cycle cost |
| Lpcd (LPCD) | លីត្រក្នុងម្នាក់ក្នុងម្ងៃ, ឯកតាបរិមាណទឹកប្រើប្រាស់ក្នុងមួយថ្ងៃក្នុងម្នាក់ |
| LWL | នីវ៉ូទឹកទាប |

| | |
|---|---|
| MCM | លានម៉ែត្រគូប |
| MD | កំណត់ត្រាប្រជុំពិភាក្សា |
| MEK-WATSAN | គំនិតផ្តួចផ្តើមការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យនៅតំបន់តាមដងទន្លេមេគង្គ |
| MEF | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| MIH | ក្រសួងឧស្សាហកម្ម និងសិប្បកម្ម |
| MIME | ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល |
| MME | ក្រសួងរ៉ែ និងថាមពល |
| MOA | ក្រសួងកសិកម្ម |
| MOE | ក្រសួងបរិស្ថាន |
| MOP | ក្រសួងផែនការ |
| MOWRAM | ក្រសួងធនធានទឹក និងឧត្តុនិយម |
| MP (M/P) | ផែនការមេ |
| MPWT | ក្រសួងសាធារណការ និងដឹកជញ្ជូន |
| MRD | ក្រសួងអភិវឌ្ឍន៍ជនបទ |
| MWL | នីវ៉ូទឹកមធ្យម |
| NCDD | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍ប្រជាធិបតេយ្យថ្នាក់ក្រោមជាតិ |
| NPRS | យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ |
| NRW | ទឹកគ្មានចំណូល |
| NSDP | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ |
| OP | គោលការណ៍ដំណើរការ |
| PAC | ប៉ូលីអាលុយមីញ៉ូមក្លរួ |
| PAP | ពលរដ្ឋរងផលប៉ះពាល់ដោយគម្រោង |
| PE | ប៉ូលីអេទីឡែន |
| PIU | អង្គភាពអនុវត្តគម្រោង |
| PMO | ការិយាល័យគ្រប់គ្រងគម្រោង |
| PMR | របាយការណ៍តាមដានគម្រោង |
| PPWSA | អង្គភាពរដ្ឋាករទឹកស្វយ័តភ្នំពេញ |
| PUR | ពោធិ៍សាត់ |
| PVC | បំពង់ប៉ូលីវីនីលក្លរួ |
| RAP | ផែនការសកម្មភាពផ្លាស់ទីលំនៅ |
| RD | នាយកដ្ឋានផ្លាស់ទីលំនៅ |
| ROW | សិទ្ធមានផ្លូវធ្វើដំណើរ |
| SCADA | ការគ្រប់គ្រងបញ្ជា និងការប្រមូលទិន្នន័យ (Supervisory Control And Data Acquisition) |
| SEC | អនុគណៈកម្មាធិការអស្សាមិករណ៍ |
| SEDP | ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម |
| SEZ | តំបន់សេដ្ឋកិច្ចពិសេស |
| SOP | និតិវិធីដំណើរការស្តង់ដារ |
| SUMS | ប្រព័ន្ធ SUMS (Synergistic Utility Management System) |
| SUR | ស្វាយរៀង |
| S/V | ការត្រួតពិនិត្យ |
| TOR | លក្ខខណ្ឌយោង |
| TPW | អង្គភាពរដ្ឋាករទឹកខេត្តកោលដៅ |
| UN | អង្គការសហប្រជាតិ |
| UNESCO | អង្គការយូណេស្កូ (អង្គការសិក្សាវិទ្យាសាស្ត្រអប់រំ និងវប្បធម៌ នៃអង្គការសហប្រជាជាតិ) |
| USGS | ភ្នាក់ងារសិក្សាស្រទាប់ដីសហរដ្ឋអាមេរិក |
| UXO | យុទ្ធភ័នមិនទាន់ផ្ទុះ |
| WB | ធនាគារពិភពលោក |
| WTP | រោងចក្រប្រព្រឹត្តិកម្មទឹកស្អាត |
| WWs | អង្គភាពរដ្ឋាករទឹក |

## ខ្នាត

| | | |
|---|---|---|
| ប្រវែង / កំរាស់ | : | គម, ម, សម, មម, មីក្រូង (μm) |
| ទំងន់ | : | មក្រ, ក្រ, គក្រ, តោន |
| ពេលវេលា | : | វិនាទី · នាទី · ម៉ោង · ថ្ងៃ · ឆ្នាំ |
| សំពាធ | : | Pa, kPa, MPa, mmAq, atm, bar |
| មាឌ | : | សម$^3$, ម$^3$, លីត្រ, លាន ម$^3$ |
| ធារទឹក (មាឌ) | : | ម$^3$/ម៉ោង, ម$^3$/នាទី, ម$^3$/ថ្ងៃ, លីត្រ/នាទី, មីលីលីត្រ/នាទី |
| ធារទឹក (ម៉ាស់) | : | គក្រ/ម៉ោង, តោន/ម៉ោង |
| ដង់ស៊ីតេ | : | គក្រ/ម$^3$, ក្រ/សម$^3$, មក្រ/លីត្រ |
| ល្បឿន | : | សម/វិនាទី, ម/វិនាទី, គម/ម៉ោង |
| ភាពអន្ទិល | : | Pa·s, mPa·s |
| ក្រឡាផ្ទៃ | : | មម$^2$, សម$^2$, ម$^2$, គម$^2$, ហត |
| ប្រេកង់ | : | Hz |
| អានុភាព | : | W, kW |
| តង់ស្យុង | : | V, kV |
| ចរន្តអគ្គិសនី | : | A, mA, kA |
| សីតុណ្ហភាព | : | degree C , degC, ℃ |
| កម្លាំងបង្វិល | : | N · m |
| ល្បឿនជុំ | : | min-1 |
| កម្លាំង | : | N |
| ប្រសិទ្ធភាព | : | % |

# ជំពូក 1. ប្រវត្តិគម្រោង

## 1-1 ប្រវត្តិគម្រោង

ក្រោយពីការអភិវឌ្ឍន៍នៃប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ក្នុងរាជធានីភ្នំពេញ ដោយរាជរដ្ឋាភិបាលកម្ពុជា (RGC) រួចមក រាជរដ្ឋាភិបាល ក៏បន្តអភិវឌ្ឍប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត នៅតាមបណ្តាទីរួមខេត្តនានា ដោយពង្រីកសមិទ្ធិផលប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតក្នុងរាជធានីភ្នំពេញ។ ភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) គាំទ្រជាបន្តបន្ទាប់ ដល់រាជរដ្ឋាភិបាល តាមរយៈសហប្រតិបត្តិការបច្ចេកទេស ជំនួយឥតសំណង និងតាមរយៈជំនួយហិរញ្ញប្បទាន (ODA Loan)។

"ផែនការមេផ្គត់ផ្គង់ទឹកស្អាតក្នុងរាជធានីភ្នំពេញ នៃព្រះរាជាណាចក្រកម្ពុជា" បានត្រូវរៀបចំឡើង បន្ទាប់ពីសង្គ្រាមស៊ីវិល ដោយមានការជ្រោមជ្រែងរបស់ JICA នាឆ្នាំ ១៩៩៣។ ដោយផ្អែកលើផែនការមេនេះ រោងចក្រប្រព្រឹត្តិកម្មទឹក និងបណ្តាញបំពង់ចែកចាយទឹកស្អាត បានត្រូវសាងសង់ តាមរយៈគម្រោងជំនួយឥតសំណងរបស់ជប៉ុន។ ការពង្រឹងរបៀបគ្រប់គ្រង របៀបដំណើរការ និងការថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត បានរីកចម្រើន ដោយមានកិច្ចសហប្រតិបត្តិការបច្ចេកទេស ជាមួយអង្គភាពទឹកស្អាត និងប្រព័ន្ធអនាម័យ នៃក្រុងគីតាគ្យូស៊ូ ជាដើម។ល។

កិច្ចសហប្រតិបត្តិការទៅវិញទៅមក ជាមួយអ្នកផ្តល់ជំនួយដទៃៗទៀត បានប្រែក្លាយអង្គភាពរដ្ឋាករទឹកស្វយ័តភ្នំពេញ ទៅជាសាជីវកម្មមួយ ក្នុងចំណោមសាជីវកម្មដែលល្អបំផុតទាំងឡាយក្នុងតំបន់អាស៊ី៖ ផ្គត់ផ្គង់ទឹកបាន ៩០% នៃតំបន់គ្រប់គ្រង, អត្រាទឹកបាត់បង់ ៨%, ផ្គត់ផ្គង់ទឹក ២៤ម៉ោងលើ២៤ម៉ោង តាមទិន្នន័យឆ្នាំ ២០០៦។ ទន្ទឹមគ្នានេះដែរ ការផ្គត់ផ្គង់ទឹកស្អាត ក្នុងទីរួមខេត្តនានា បានតែ ៣៥% ប៉ុណ្ណោះ ក្នុងឆ្នាំ ២០០៥។

គោលដៅជំរុញអត្រាទទួលបានសេវាទឹកស្អាត ក្នុងតំបន់ទីប្រជុំជន អោយដល់ ១០០% ត្រឹមឆ្នាំ ២០២៥ ត្រូវបានផ្សព្វផ្សាយក្នុងក្រសួងឧស្សាហកម្ម និងសិប្បកម្ម ហើយរាជរដ្ឋាភិបាល កំពុងតែបន្តពង្រីកប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត តាមទីរួមខេត្តនានា។

ជាលទ្ធផល ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត អាចដំណើរការបានក្នុងកម្រិតមួយ។ ប៉ុន្តែអត្រាគ្របដណ្តប់សេវាកម្មក្នុងក្រុងតាមខេត្ត នៅទាបនៅឡើយ ដោយសារតែសមត្ថភាពផលិតទឹកស្អាត នៅទាប។

## 1-2 ស្ថានភាពធម្មជាតិ

ការសិក្សាសណ្ឋានដី និងផ្លូវ, ការសិក្សាភូគព្ភសាស្ត្រ, ការសិក្សាគុណភាពទឹក និងលំហូរទឹកស្ទឹង ដែលរៀបរាប់ខាងក្រោម បានត្រូវគេធ្វើឡើង ដើម្បីកំណត់លក្ខខណ្ឌរចនាប្លង់គម្រោង ចំពោះទីតាំងគម្រោងដែលបានស្នើរឡើង។ ស្ថានភាពបរិស្ថានដែលមានស្រាប់ នៅទីតាំងគម្រោង មានរៀបរាប់ក្នុងផ្នែក "1.3 ការសិក្សាបរិស្ថាន និងសង្គម"។

### 1-2-1 ការសិក្សាសណ្ឋានដី និងបណ្តាញផ្លូវ

<u>ការសិក្សាសណ្ឋានដី</u>

ការវាស់សណ្ឋានដី បានត្រូវធ្វើនៅទីតាំងសម្រាប់ស្ថានីយបូមទឹកឆៅ និងរោងចក្រប្រព្រឹត្តកម្មទឹកថ្មី។ ចំពោះសណ្ឋានដីទីតាំងសម្រាប់ស្ថានីយបូមទឹកឆៅ គេវាស់មុខកាត់ទទឹងស្ទឹង ដើម្បីស្វែងយល់ពីស្ថានភាពបាតស្ទឹងនៅក្បែរច្រាំង។ ជាមួយគ្នានេះដែរ គេ ក៏វាស់ផ្ទៃរាប ដើម្បីរចនាសំណង់ទប់ច្រាំងនៅម្តុំស្ថានីយបូមទឹកឆៅថ្មី និងទំហំជញ្ជាំងទប់ទឹកបណ្តោះអាសន្នពេលសាងសង់។

<u>ការសិក្សាបណ្តាញផ្លូវ</u>

ការវាស់វែងបណ្តាញផ្លូវ បានត្រូវគេធ្វើទៅតាមផ្លូវរត់បណ្តាញបំពង់។ ដោយសារតំបន់នេះ ជាតំបន់រាបស្មើរ គេចាំបាច់ធានាអោយមានសំពាធទឹកគ្រប់គ្រាន់ ក្នុងផែនការបណ្តាញបំពង់ចែកចាយទឹក។

### 1-2-2 ការសិក្សាស្រទាប់ដី

<u>សំណើរទីតាំងស្ថានីយបូមទឹកឆៅ</u>

ស្រទាប់ដីពីផ្ទៃលើចុះទៅដល់ 4.0ម ~ 4.5ម ជាប្រភេទដីស្អិត (cohesive soil) ហើយជ្រៅជាងនេះ ជាស្រទាប់កណ្តាល ដែលជាដីឥដ្ឋល្បាយខ្សាច់ និងដីខ្សាច់ល្បាយដីឥដ្ឋ។ មេគុណ N នៃស្រទាប់ដីផ្ទៃលើដែលត្រូវជីករហូតដល់ជម្រៅដែលចង់បាន មានតម្លៃប្រហែល 10 ហើយគេអាចប្រើគ្រឿងចក្រ backhoe ដើម្បីជីក។

<u>សំណើរទីតាំងរោងចក្រប្រព្រឹត្តកម្មទឹក</u>

ស្រទាប់ដីពីផ្ទៃលើចុះទៅដល់ជម្រៅ 8.5ម ~ 9.5ម ជាប្រភេទដីឥដ្ឋល្បាយខ្សាច់ នៅចំនុចក្បែរទីតាំងរោងចក្រប្រព្រឹត្តកម្មទឹក ហើយជ្រៅជាងនេះ ជាស្រទាប់កណ្តាល ដែលជាដីឥដ្ឋល្បាយខ្សាច់ និងដីខ្សាច់ល្បាយដីឥដ្ឋ។ ប្រភេទដីខ្សាច់ល្បាយដីឥដ្ឋ មានគ្រួសល្អិតៗលាយឡំជាមួយបន្តិចបន្តួច។

មេគុណ N នៃស្រទាប់ដីផ្ទៃលើដែលត្រូវជីករហូតដល់ជម្រៅដែលចង់បាន នៅទីតាំងរោងចក្រប្រព្រឹត្តកម្មទឹកមានតម្លៃប្រហែល 20 ហើយគេអាចប្រើគ្រឿងចក្រ backhoe ដើម្បីជីក។ ស្រទាប់ដីឥដ្ឋជ្រៅជាង 8.5 ~ 9.5 ម ដែលមានមេគុណ N ធំជាង 50 នឹងក្លាយជាស្រទាប់រង់ទំងន់តាមរយៈគ្រឹះសសរ របស់អាគាររដ្ឋបាលជាដើម ក្នុងរោងចក្រប្រព្រឹត្តកម្មទឹក។

### 1-2-3 ការសិក្សាអំពីគុណភាពទឹក

ការវាស់គុណភាពទឹកស្ទឹងពោធិ៍សាត់ដែលចាត់ជាប្រភពទឹកមេ បានធ្វើឡើងរៀងរាល់ខែ ចាប់ពីខែកក្កដា ឆ្នាំ 2017 ដែលលទ្ធផលមានបង្ហាញក្នុង តារាង 1-3-3 និង តារាង 1-3-4។ គុណភាពទឹក នៅក្បែរទីតាំងស្ថានីយបូមទឹកនៅ មានសង្ខេបដូចខាងក្រោមៈ

- ភាពល្អក់ មានកម្រិតខ្ពស់ពេញមួយឆ្នាំ ដែលខ្ពស់ជាង 50 NTU ជានិច្ច។ ទឹក មានពណ៌ត្នោត។
- សារធាតុគ្រោះថ្នាក់ មិនត្រូវបានរកឃើញឡើយ។
- កំហាប់អាលុយមីញ៉ូម និងដែក មានកម្រិតខ្ពស់ ដែលលាយឡំជាមួយសារធាតុល្អក់។
- BOD ជាប៉ារ៉ាម៉ែត្របញ្ជាក់ពីការបំពុលដោយសំណល់រាវចេញពីលំនៅដ្ឋាន។ វាមានកម្រិតទាប។
- អ៊ីយ៉ុងអាម៉ូញ៉ូម រកឃើញនៅគ្រប់ការវិភាគ ក្នុងកម្រិតទាប (0.01 – 0.23 មក្រ/ល)។

យោងតាមការសិក្សាប្រចាំខែនៃគុណភាពទឹកស្ទឹងពោធិ៍សាត់ ឃើញថាមិនមានសារធាតុគ្រោះថ្នាក់ ដែលពិបាកធ្វើប្រព្រឹត្តកម្មសម្អាត ក្នុងទឹកប្រភពឡើយ។ ភាពល្អក់មានកម្រិតខ្ពស់ ដែលមិនអាចផឹកបាន ប៉ុន្តែវានឹងមានកម្រិតសមរម្យ បន្ទាប់ពីដំណើរការប្រព្រឹត្តកម្ម។

### 1-2-4 ការវាស់ធារទឹកស្ទឹង

ការវាស់ធារទឹក បានធ្វើឡើងពីខែមិថុនា ដល់ខែតុលា ឆ្នាំ 2017 ដើម្បីពិនិត្យបរិមាណទឹកដែលត្រូវបូម។

ធារទឹកស្ទឹង នៅទំនប់ដំណាក់អំពិល ត្រូវបានប៉ាន់ស្មានថាមានបរិមាណ ទាបជាង 9 ~ 9.5ម$^3$/វ បន្តិច ក្នុងឆ្នាំ 2015 ដែលជាឆ្នាំដែលមានភាពរាំងស្ងួតខ្លាំងថ្មីជាងគេ។

ចំណែកឯផែនការរបស់ ADB ទាក់ទងនឹងប្រព័ន្ធស្រោចស្រពដំណាក់ឈើក្រំ (DCIS)[1)] បានត្រូវគេរៀបចំឡើង ដោយផ្អែកលើខួបរចនានៃភាពរាំងស្ងួត ដែលមានខួបត្រលប់មកវិញ 5 ឆ្នាំ។ ក្នុងផែនការនេះ ករណីមានការអភិវឌ្ឍន៍ DCIS ក្រោមប្រព័ន្ធស្រោចស្រពដំណាក់អំពិលដែលមានស្រាប់ (DAIS) នោះធារទឹកធម្មតាកម្រិត 4.74 ម$^3$/វ នឹងត្រូវបង្ហូរពីទំនប់ដំណាក់អំពិលចូលក្នុងស្ទឹងពេញឆ្នាំ ទោះក្នុងខួបរាំងស្ងួតត្រលប់មកវិញ 5 ឆ្នាំ ក៏ដោយ។

ផ្អែកលើការវិភាគខាងលើ បរិមាណទឹកបូមសម្រាប់ផលិតផ្គត់ផ្គង់តាមលំនៅដ្ឋាន (មានស្រាប់ 7,260 ម$^3$/ថ្ងៃ x 1.1 =7,986 ម$^3$/ថ្ងៃ, ថ្មី 6,600 ម$^3$/ថ្ងៃ x 1.1 =7,260 ម$^3$/ថ្ងៃ, ជាសរុប 15,246 ម$^3$/ថ្ងៃ = 0.18 ម$^3$/វ) អាចត្រូវបានធានា ទោះក្នុងខួបរាំងស្ងួតត្រលប់មកវិញ 10 ឆ្នាំ ក៏ដោយ។

---

[1] ADB TA 6456-REG: Preparing the Greater Mekong Sub region Flood and Drought Risk Management and Mitigation Project, Irrigation Engineers Report (May 2012)។ 0.26ម$^3$/វិនាទី ផ្អែកលើបទបង្ហាញទាក់ទងនឹងធារាសាស្ត្រនៃគម្រោង River Basin Water Resources Utilization Project របស់ JICA។

## 1-3 ការសិក្សាបរិស្ថាន និងសង្គម

### 1-3-1 សមាសភាពគម្រោង និងប្រភេទបរិស្ថានរបស់ JICA

គម្រោងនេះ ជាគម្រោងពង្រីកប្រព័ន្ធចែកចាយទឹកស្អាត ដែលមានស្រាប់ ដោយយោងលើសំណើរពីរដ្ឋាភិបាលកម្ពុជា។ វាមិនស្ថិតក្នុងគម្រោងផ្គត់ផ្គង់ទឹកស្អាត, គម្រោងប្រព័ន្ធអនាម័យ និងគម្រោងប្រព្រឹត្តកម្ម ដែលមានលក្ខណៈរសើប ឬស្ថិតក្នុងតំបន់រសើប ដែលមានចែងក្នុងគោលការណ៍ណែនាំ JICA សម្រាប់ការសិក្សាបរិស្ថាន និងសង្គម (ខែមេសា ឆ្នាំ ២០១០; អំណេះតទៅហៅថា គោលការណ៍បរិស្ថាន JICA) ។ ផ្អែកលើគោលការណ៍បរិស្ថាន JICA នេះ គម្រោងនេះ ចូលចំណាត់ថ្នាក់បរិស្ថានប្រភេទ B។

យោងតាមការប្រឹក្សាជាមួយក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងក្រសួងបរិស្ថាន គម្រោងនេះត្រូវការ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង (IEIA) ទៅតាមបញ្ញត្តិកម្ពុជា។ ដូចនេះ គម្រោងសិក្សានេះ បានជួយគាំទ្រការរៀបចំ IEIA។

មានសមាសភាពគម្រោងបី ដែលត្រូវគេចាត់ថាអាចប៉ះពាល់ដល់ស្ថានភាពបរិស្ថាន និងសង្គម គឺ (1) ការសាងសង់ស្ថានីយបូមទឹកនៅ រោងចក្រប្រព្រឹត្តកម្មទឹក ការងារដំឡើងបំពង់ (2) ការងារដំណើរការស្ថានីយបូមទឹកនៅ និងរោងចក្រប្រព្រឹត្តកម្មទឹក និង (3) អ្នកទទួលផលពីគម្រោង។

### 1-3-2 ស្ថានភាពបរិស្ថាន និងសង្គម ជាមូលដ្ឋាននានា

កម្ពុជា (ឈ្មោះផ្លូវការះ ព្រះរាជាណាចក្រកម្ពុជា) ជាប្រទេសមួយដែលស្ថិតនៅភាគខាងត្បូងនៃឧបទ្វីបឥណ្ឌូចិន នៃអាស៊ីអាគ្នេយ៍។ ស្ថិតក្នុងតំបន់ត្រូពិច ដែលរងឥទ្ធិពលអាកាសធាតុខ្យល់មូសុង កម្ពុជាមានរដូវពីរដាច់ពីគ្នា គឺរដូវវស្សា និងរដូវប្រាំង។ តំបន់គម្រោង មានបង្ហាញក្នុងរូបខាងក្រោម។




**រូប 1-3-1 តំបន់គម្រោង**

### 1-3-2-1 តំបន់ការពារ

នៅកម្ពុជា “រាជក្រិត ស្តីអំពីតំបន់ការពារធម្មជាតិ ចេញឆ្នាំ ១៩៩៣” ជាច្បាប់ដំបូង ដែលកំណត់តំបន់ការពារធម្មជាតិ។ រាជក្រិតនេះ បានបែងចែកតំបន់ការពារធម្មជាតិ ទាំង ២៣ ទីតាំង ជា ៤ ប្រភេទ។

នាឆ្នាំ ២០០៨ “ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ” បានត្រូវប្រកាសជាធរមាន។ ច្បាប់នេះ បែងចែកគោលបំណងការពារ ជា ៨ ប្រភេទ និង តំបន់គ្រប់គ្រង ជា ៤ តំបន់។ ម្យ៉ាងទៀត នាឆ្នាំ ២០១៧ “អនុក្រិតស្តីពីរបៀងអភិរក្សជីវចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិ នៃព្រះរាជាណាចក្រកម្ពុជា” បានត្រូវអនុម័ត ដែលធ្វើអោយផ្ទៃដីប្រហែល ៤០%នៃប្រទេស ក្លាយជាតំបន់ការពារធម្មជាតិ។ ផែនទីខាងក្រោម បង្ហាញពីតំបន់ការពារនានា។




**រូប 1-3-2 តំបន់ការពារក្នុងព្រះរាជាណាចក្រកម្ពុជា**

ប្រភព៖ អនុក្រិត ស្តីពីការបង្កើតរបៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិ

មានតំបន់ការពារ ក្នុងខេត្តពោធិ៍សាត់ ដែលស្ថិតនៅក្បែរបឹងទន្លេសាប និងតំបន់ព្រៃ នៅភាគខាងត្បូង។ គេមិនឃើញមានតំបន់ការពារ នៅក្បែរតំបន់គម្រោងឡើយ។ ក្រុមសិក្សា បានទទួលបានការបញ្ជាក់ពីមន្ទីរបរិស្ថានខេត្តពោធិ៍សាត់ ថាគ្មានតំបន់ការពារ នៅក្នុងតំបន់គម្រោងឡើយ។

មានតំបន់អភិរក្សជីវៈចម្រុះសំខាន់ៗ ចំនួន ៤០ (Key Biodiversity Areas [KBAs]) ដែលចាត់ទុកជាតំបន់សំខាន់សម្រាប់អភិរក្សជីវៈចម្រុះ និងមានទីតាំងចំនួន 36ផ្សេងក្រៅពី តំបន់ KBAsដែលជាតំបន់សំខាន់អភិរក្សបក្សី (Important Bird Areas [IBAs])។ តំបន់អភិរក្ស KBAដែលនៅជិតតំបន់គម្រោងបំផុត គឺ ដីរនាត ដែលស្ថិតលើត្រើយបឹងទន្លេសាប មានចម្ងាយជាង ១០ គម ពីតំបន់គម្រោង។

### 1-3-2-2 បេតិកភណ្ឌវប្បធម៌ ។ល។

មានតំបន់សំខាន់ៗ ចំនួនបី ដែលបានបញ្ចូលជាតំបន់បេតិកភណ្ឌពិភពលោក របស់ UNESCO ដូចជា តំបន់អង្គរ ប៉ុន្តែទីតាំងទាំងនេះ ស្ថិតនៅចំងាយជាង ១០០ គម ពីតំបន់គម្រោង។

### 1-3-2-3 ស្ថានភាពបរិស្ថានធម្មជាតិ

កម្ពុជា សំបូរទៅដោយបរិស្ថានធម្មជាតិ និងតំបន់អេកូឡូស៊ីសំខាន់ៗជាច្រើន ដូចជា បឹងទន្លេសាប ទន្លេមេគង្គ និងដៃទាំងឡាយរបស់វា។ ដូចដែលបានរៀបរាប់ខាងដើម រដ្ឋាភិបាលកម្ពុជា បានកំណត់ផ្ទៃដីជាង ៤០%នៃផ្ទៃដីសរុប ជាតំបន់ការពារ ក្នុងការប្រឹងប្រែងអភិរក្សបរិស្ថានធម្មជាតិ។ ក្នុងបរិស្ថានសំបូរបែបបែបនេះ មានពពួកសត្វរុក្ខជាតិជាច្រើនប្រភេទ ដែលរងការគម្រាមកំហែង។ តារាងបន្ទាប់នេះ បង្ហាញពពួកសត្វរុក្ខជាតិ ដែលជិតផុតពូជ (CR) និងកំពុងរងគ្រោះ (EN) ក្នុងប្រទេសកម្ពុជា។

**តារាង 1-3-1 ពពួកសត្វរុក្ខជាតិរងការគម្រាមកំហែង ក្នុងប្រទេសកម្ពុជា**

| ស្ថានភាព | | ចំណាត់ថ្នាក់ | ចំនួន | ប្រភេទ |
|---|---|---|---|---|
| ជិតផុតពូជ Critically Endangered )CR( | ពពួកសត្វ | ថនិកសត្វ | 5 | រមាស Sumatran Rhinoceros ។ល។ |
| | | បក្សី | 7 | ត្មាតខ្មៅឥណ្ឌា) Indian Black Vulture( ។ល។ |
| | | ត្រី | 6 | ត្រីរាជ) Mekong Giant Catfish (។ល។ |
| | | កង្កែប | 4 | Damleis |
| | | លូន | 4 | អណ្តើកហ្លួង (Common Batagur(។ល។ |
| | ពពួករុក្ខជាតិ | រុក្ខជាតិមានសរសៃរនាំ (Vascular plant) | 8 | ដើមចន្ទន៍ក្រស្នា (Agar Wood) ។ល។ |
| កំពុងរងគ្រោះ Endangered )EN( | ពពួកសត្វ | ថនិកសត្វ | 14 | ក្តាន់ឥណ្ឌា (Indian Hog Deer) ។ល។ |
| | | បក្សី | 10 | ចាបព្រៃវែង )Yellow-breasted Bunting(។ល។ |
| | | លូន | 3 | អណ្តើកព្រិច )Elongated Tortoise(។ល។ |
| | | កង្កែប | 2 | Musical leaf-litter toad ។ល។ |
| | | ត្រី | 13 | ត្រីត្រសក់ក្រហម) Jullien's Golden Carp (។ល។ |
| | | ផ្កាថ្ម) Corals( ឈ្លើងសមុទ្រ) sea cucumber( | 7 | Golden Sandfish ។ល។ |
| | ពពួករុក្ខជាតិ | រុក្ខជាតិមានសរសៃរនាំ (Vascular plant) | 17 | គគីរភ្នំ) White Meranti (។ល។ |

ប្រភព៖ បញ្ជីក្រហមអង្គការសហប្រជាជាតិដើម្បីការអភិរក្សធម្មជាតិ (IUCN Red List)

តំបន់គម្រោង និងជុំវិញតំបន់នោះ ជាតំបន់ប្រជុំជន និងដីកសិកម្ម។ មានតែតំបន់តូចមួយ មានព្រៃដែលដុះឡើងវិញ (Secondary Forest) ដែលស្ថិតក្នុងផ្ទៃកមួយ នៃផ្ទៃដីមិនមានការដាំដុះ។ តំបន់នោះ មើលឃើញវាលស្រែដ៏ស្រស់បំព្រង និងទេសភាពបែបស្រុកស្រែ ប៉ុន្តែគេចាត់ទុកវាជាតំបន់ធម្មជាតិ ដែលមានការកែប្រែខុសពីធម្មជាតិដើម (artificial modification)។

តំបន់គម្រោង ស្ថិតក្នុងទំនាបលិចទឹកពីស្ទឹងពោធិ៍សាត់ ដែលហូរចាក់ចូលបឹងទន្លេសាប នៅផ្នែកខាងលិច។ ហើយវាមានសណ្ឋានរៀបស្មើ។ ផ្នែកខ្សែទឹកខាងលើ នៃស្ទឹងពោធិ៍សាត់ ត្រូវគេចាត់ជាតំបន់ការពារដែលសំបូរដោយប្រព័ន្ធអេកូឡូស៊ី។ម្យ៉ាងវិញទៀត តំបន់គម្រោង មិនមានព្រៃគួរអោយកត់សម្គាល់ទេ ដូច្នេះ ជម្រកសត្វ គឺជាដីដាំដុះ កុម្ពោតព្រៃ ស្ទឹង និងព្រៃតាមមាត់ស្ទឹង។ ការសិក្សាលើប្រព័ន្ធអេកូឡូស៊ីបានត្រូវធ្វើ ដោយការស៊ើបសួរព័ត៌មាន និងចុះពិនិត្យផ្ទាល់នៅទីតាំងផ្ទាល់។ លទ្ធផល មានសង្ខេបដូចខាងក្រោម។

**(1) បក្សី**

បក្សីចំនួន ៤៩ ប្រភេទ ត្រូវគេកត់ត្រា និងចាត់ទុកជាប្រភេទមិនងាយរងគ្រោះ (Least Concern (LC)) ក្នុង បញ្ជីក្រហមអង្គការសហប្រជាជាតិដើម្បីការអភិរក្សធម្មជាតិ **(IUCN Red List)** និងមិនស្ថិតក្នុងប្រភេទណាមួយ ក្នុងបញ្ជីនៃអនុសញ្ញានៃការធ្វើពាណិជ្ជកម្មអន្តរជាតិនៃប្រភេទសត្វ និងរុក្ខជាតិព្រៃដែលកំពុងរងគ្រោះជាសកល (CITES[2] List) ទេ។ ប្រភេទសត្វទាំងនេះ មានជាទូទៅ និងមានច្រើន។ ប្រភេទដែលឃើញមាននៅទីតាំងគម្រោង ជាពពួកបក្សី ដែលចូលចិត្តនៅទីតាំងវាល មានដំណាំ និងដីសើម ដូចជា ក្រួចអិនវាលស្រែតូច (Paddyfield Pitpit), ចាបចង្រុងទ្រូងស្រកា (Scaly-breasted Munia), ចាបតេត (Common Tailorbird)។ ប្រភេទសត្វទាំងនេះ មានជម្រកនៅក្នុងតំបន់គម្រោង។ ប៉ុន្តែ មិនមានដង់ស៊ីតេចំនួនច្រើនទេ។

**(2) ល្មូន និងកង្កែប**

មានពពួកកង្កែប ១១ ប្រភេទ និងពពួកល្មូន 7 ប្រភេទ។ យោងតាម IUCN Red List ពួកវាទាំងអស់ ស្ថិតក្នុងប្រភេទ LC និងមិនស្ថិតក្នុង CITES ទេ។

**(3) ត្រី**

ការសិក្សា បានត្រូវធ្វើឡើង នៅសង្កាត់លលក ស ចំហៀងស្ទឹងពោធិ៍សាត់ ដោយការស៊ើបសួរ និងចុះសិក្សាផ្ទាល់នៅក្នុងស្ទឹង។ ជាលទ្ធផល មានត្រី ១១២ ប្រភេទ ក្នុងនោះ ២ ប្រភេទ កំពុងរងគ្រោះ (Endangered species), ៤ ប្រភេទ ងាយរងគ្រោះ (Vulnerable species), ៤ ប្រភេទ ជិតរងគ្រោះ (Near Threatened species) និង ១០២ ប្រភេទ មិនងាយរងគ្រោះ (Least Concern species) នៅក្នុងបញ្ជីក្រហម IUCN Red List។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មាន Red List ផ្ទាល់ខ្លួន ដោយបានចាត់ទុក ត្រីត្រសក់ (Thicklip barb) ជាប្រភេទជិតផុតពូជ (critical endangered) និងត្រីក្របី (Dwarf goonch) ជាប្រភេទងាយរងគ្រោះ (vulnerable)។

**1-3-2-4 គុណភាពខ្យល់**

មិនទាន់មានកម្មវិធី តាមដានគុណភាពខ្យល់ នៅតំបន់នេះទេ។ មន្ទីរបរិស្ថានខេត្តពោធិ៍សាត់ មិនមានឧបករណ៍ និងកម្លាំងពលកម្ម សម្រាប់ធ្វើការងារនេះទេ។ ដូច្នេះ ការវាស់គុណភាពខ្យល់ នឹងត្រូវធ្វើ ដោយក្រុមសិក្សារបស់ក្រសួងបរិស្ថាន ប្រសិនបើមានការចាំបាច់។

មិនទាន់ឃើញមានការអភិវឌ្ឍន៍បែបឧស្សាហកម្មនៅឡើយទេ ក្នុងតំបន់គម្រោង ដែលនាំអោយការបំពុលខ្យល់ មានកម្រិតទាបណាស់។ ការបំពុលខ្យល់ គឺមានតែពីយានយន្ត។ ផ្លូវជាតិលេខ៥ ឆ្លងកាត់ក្រុង

---

[2] អនុសញ្ញានៃការធ្វើពាណិជ្ជកម្មអន្តរជាតិនៃប្រភេទសត្វ និងរុក្ខជាតិព្រៃដែលកំពុងរងគ្រោះជាសកល

ពោធិ៍សាត់។ ចរាចរណ៍យានយន្ត ក៏មិនមានច្រើនណាស់ណាដែរ ដែលនាំអោយការបំពុលខ្យល់ដោយយានយន្ត នៅក្នុងកម្រិតទាប។ ម្យ៉ាងទៀត សណ្ឋានបរិស្ថាននៅតំបន់នេះ មិនអំណោយផល អោយខ្យល់ពុលទាំងនោះ នៅក្នុងតំបន់គម្រោងឡើយ។ ដូច្នេះ គេរំពឹងថា គុណភាពខ្យល់ក្នុងតំបន់គម្រោង មានកម្រិតល្អ។

ក្រុមសិក្សា បានស្នើក្រុមសិក្សានៃ ក្រសួងបរិស្ថាន វាស់គុណភាពខ្យល់ ដែលបានអនុវត្តនាថ្ងៃទី ២ ខែកុម្ភៈ ឆ្នាំ ២០១៨ និងបានលទ្ធផលដូចតារាងខាងក្រោម៖

**តារាង 1-3-2 លទ្ធផលវាស់គុណភាពខ្យល់ (mg/ m³)**

| ប៉ារ៉ាម៉ែត្រ | | ទីតាំង 1 | ទីតាំង2 | ស្តង់ដារកម្ពុជា | ស្តង់ដារបរិស្ថានជប៉ុន (មធ្យមភាគ ក្នុង 24 ម៉ោង) |
|---|---|---|---|---|---|
| កាបូនម៉ូណូអុកស៊ីត | CO | 0.85 | 0.50 | 20 (មធ្យមភាគ ក្នុង 8 ម៉ោង) | 10 |
| អាសូតឌីអុកស៊ីត | NO2 | 0.011 | 0.009 | 0.1 (មធ្យមភាគ ក្នុង 24 ម៉ោង) | 0.04～0.06 ឬតិចជានេះ |
| ស្ពាន់ធ័រឌីអុកស៊ីត | SO2 | 0.006 | 0.004 | 0.3 (មធ្យមភាគ ក្នុង 24 ម៉ោង) | 0.04 |
| សារធាតុមិនរងសរុប | TSP | 0.150 | 0.094 | 0.33 (មធ្យមភាគ ក្នុង 24 ម៉ោង) | 0.1（SPM:10μm >） |

ប្រភព៖ ក្រុមសិក្សា JICA

លទ្ធផលនៃគ្រប់ប៉ារ៉ាម៉ែត្រ ឆ្លើយតបតាមស្តង់ដារកម្ពុជា និងទាបជាងតម្លៃស្តង់ដារបរិស្ថានជប៉ុនផងដែរ។ ស្តង់ដារជប៉ុន ចំពោះសារធាតុមិនរង សំដៅលើសារធាតុ ដែលមានទំហំអង្កត់ផ្ចិត តូចជាង ១០ មីក្រូម៉ែត្រ ដែលគេមិនវាស់វាផ្ទាល់ទេ។ ស្តង់ដារជប៉ុនអំពីសារធាតុមិនរងសរុប ប្រើសម្រាប់សារធាតុ ដែលមានអង្កត់ផ្ចិតតូចជាង ១០ មីក្រូម៉ែត្រ ដូច្នេះមិនប្រើជាតម្លៃប្រៀបបានទេ។ TSP អាចនឹងមានភាគល្អិតធំៗ ដូច្នេះ លទ្ធផល TSP គឺស្ថិតក្នុងកម្រិតដែលអាចទទួលយកបាន។

### 1-3-2-5 ការប្រើប្រាស់ទឹក និងគុណភាពទឹក

មានប្រភពទឹកលើដីជាច្រើន ដូចជា ស្ទឹងពោធិ៍សាត់ ដែលហូរពីលិចទៅកើត និងប្រឡាយស្រោចស្រពនានា ដែលប្រើប្រាស់ទឹកស្ទឹងពោធិ៍សាត់។ មិនមានការប្រើប្រាស់ជាទូទៅនូវទឹកក្រោមដីទេ នៅតំបន់នេះ ពីព្រោះគ្មានប្រភពទឹកក្រោមដីល្អទេ ដោយសារហេតុផលស្ថានភាពភូគព្ភសាស្ត្រតំបន់នេះ។ ការប្រើប្រាស់ទឹកក្រោមដី មានដោយផ្នែកប៉ុណ្ណោះ។ តាមរយៈលទ្ធផលសិក្សាសង្គម ប្រហែល ៦០% នៃប្រជាជនដែលរស់នៅក្រៅតំបន់ផ្គត់ផ្គង់ទឹកបច្ចុប្បន្ន ប្រើទឹកភ្លៀងសម្រាប់ផឹក, ៩%ប្រើទឹកអណ្តូង, ៤%ប្រើទឹកលើដី និង២%ប្រើទឹកអណ្តូងលូ សម្រាប់ផឹក។ ១៦%ទៀត ទិញទឹកប្រើ។ ម្យ៉ាងទៀត ប្រជាជន ដែលទទួលសេវាទឹកស្អាតពីរដ្ឋាករទឹកខេត្ត និយាយថាពួកគេ ប្រើទឹកភ្លៀងជាប្រភពទឹកបន្ទាប់បន្សំសម្រាប់ផឹក។ ចំណែក

១៥% នៃប្រជាជនដែលប្រើទឹករង្គាករទឹក បានឆ្លើយថា ពួកគាត់ប្រើទឹកសុទ្ធងប ជាប្រភពទឹកចម្បង សម្រាប់ផឹក។

មិនមានឃើញការនេសាទជាលក្ខណៈអាជីវកម្មទេ មានតែការស្ទូចត្រីបែបកំសាន្ត និងការនេសាទលក្ខណៈគ្រួសារ។ ក្នុងពេលចុះសិក្សាជាក់ស្តែង គេឃើញមានការបោកសម្លៀកបំពាក់ និងក្មេងចុះលេង ក្នុងទឹកប្រឡាយស្រោចស្រព។

ឧស្សាហកម្មចម្បង នៅពោធិ៍សាត់ គឺកសិកម្ម ជាពិសេស កសិកម្មស្រូវ។ ដូចនេះ មានការបារម្ភអំពីការបំពុលទឹក ដោយគីមីកសិកម្ម។ ថ្នាំសម្លាប់សត្វល្អិត ដែលប្រើភាគច្រើន ជាផលិតផលវៀតណាម និងថៃ។ លើសពីនេះ ក៏មានផលិតផលនាំចូលមកពី ចិន ជប៉ុន និងអឺរ៉ុបផងដែរ។ មានតែផលិតផលជី ដែលបានចុះបញ្ជីជាមួយក្រសួងបរិស្ថានប៉ុណ្ណោះ អាចប្រើប្រាស់បាននៅកម្ពុជា ប៉ុន្តែ ក៏មានការរាយការណ៍ថាមានការប្រើប្រាស់ខុសច្បាប់ នូវផលិតផល ដែលមិនបានចុះបញ្ជីត្រឹមត្រូវដែរ [3]។ ការធ្វើស្រែ ភាគច្រើន តែមួយរដូវ កម្រពីររដូវណាស់ នៅតំបន់នេះ។ ជាទូទៅ កសិករ ដាក់ជី និងបាញ់ថ្នាំសម្លាប់សត្វល្អិត ១ ខែបន្ទាប់ពីដាំ។ ហើយដោយសារ វាជាពេលវេលា ដែលត្រូវប្រើប្រាស់គីមីកសិកម្ម កសិករទាំងឡាយ ដាក់គីមីកសិកម្មបន្ថែម នៅពេលក្រោយ។ កសិករខ្លះដាំឪឡឹក នៅរដូវប្រាំង ។ល។ ប៉ុន្តែ ការប្រើប្រាស់គីមីកសិកម្ម មានកម្រិតទាប។ អញ្ចឹង ក្រុមសិក្សា ចាត់ទុកថា រយៈពេលបំពុលខ្លាំងបំផុត គឺ ១ ខែ បន្ទាប់ពីដាំដំណាំ និងបានសម្រេចយកសំណាកមកវិភាគ នៅថ្ងៃទី ១៨ ខែកក្កដា ដោយយោងតាមលទ្ធផលសម្ភាសមន្ទីរកសិកម្មខេត្ត (DOA) និងកសិករ។ ដោយសារគ្មានមន្ទីរពិសោធន៍ណាមួយក្នុងប្រទេសកម្ពុជា អាចវិភាគកម្រិតថ្នាំសម្លាប់សត្វល្អិតបាន ក្រុមសិក្សា បានយកសំណាក ទៅពិនិត្យនៅជប៉ុន ដោយមន្ទីរពិសោធន៍ដែលមានអាជ្ញាប័ណ្ណ និងមានបទពិសោធន៍ត្រឹមត្រូវ។ គ្រប់ប៉ារ៉ាម៉ែត្រ នៃថ្នាំសម្លាប់សត្វល្អិត ទាំង ១៨ ដែលមានចែងក្នុង ស្តង់ដារគុណភាពទឹកផឹកកម្ពុជា (២០០៤) [4] និងទាំង ៣២៨ ដែលតែងតែរកឃើញនៅជប៉ុន បានត្រូវវិភាគ ហើយជាលទ្ធផល មិនឃើញមានថ្នាំសម្លាប់សត្វល្អិតណាមួយទេ។ ដូច្នេះ យើងអាចសន្និដ្ឋានថា ថ្នាំសម្លាប់សត្វល្អិត ប្រើក្នុងកសិកម្មស្រូវ មិនបានបំពុលប្រភពទឹកគួរឲ្យកត់សម្គាល់ទេ។

ការវិភាគគុណភាពទឹក ពីស្ទឹងពោធិ៍សាត់ ដែលជាប្រភពទឹកមេ ធ្វើឡើងរៀងរាល់ខែ តាំងពីខែ កក្កដា ឆ្នាំ ២០១៧ ដល់ខែ ឧសភា ២០១៨ ដែលលទ្ធផលវិភាគ មានសង្ខេបក្នុងតារាងដូចខាងក្រោម។ គុណភាពទឹកក្បែរទីតាំងគ្រោងធ្វើស្ថានីយបូមទឹកឆៅ អាចសង្ខេបដូចខាងក្រោម។

[3] V. Preap, et. Al. (2015), “ការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិតបច្ចុប្បន្ន លើផលិតផលកសិកម្ម ក្នុងប្រទេសកម្ពុជា”, FFTC-KU International

[4] ស្តង់ដារគុណភាពទឹកផឹកកម្ពុជា (២០០៤) បានធ្វើបច្ចុប្បន្នភាព នាឆ្នាំ២០១៥។ ស្តង់ដារថ្មី មិនបានបញ្ចូលប៉ារ៉ាម៉ែត្រថ្នាំសម្លាប់សត្វល្អិត ពីព្រោះប៉ារ៉ាម៉ែត្រទាំងនោះ មិនអាចតាមដានបាននៅកម្ពុជា។ ក្រុមសិក្សា យកឯកសារចាស់មកយោង ដោយសារ មិនឯកសារផ្សេងដែលអាចប្រើប្រាស់បាន។

- ភាពល្អក់ទឹក ខ្ពស់ ពេញមួយឆ្នាំ ដែលមានកម្រិត ខ្ពស់ជាង 50 NTU។ ទឹកមានពណ៌ត្នោត។
- សារធាតុគ្រោះថ្នាក់ មិនបានរកឃើញឡើយ។
- កំហាប់អាលុយមីញ៉ូម និងដែក មានកម្រិតខ្ពស់ ដែលនៅលាយឡំនឹងជាតុល្អក់។
- BOD ដែលជាសន្ទស្សន៍បញ្ជាក់ថាមានការបំពុលដោយសំណល់រាវពីលំនៅដ្ឋាន មានកម្រិតទាប។
- ប៉ារ៉ាម៉ែត្រ ដែលបញ្ជាក់ពីការបំពុលដោយសំណល់រាចេញពីលំនៅដ្ឋាន ដូចជា កូលីហ្វម អ៊ីកូឡាយ និងអាម៉ូញាក់ ត្រូវគេសង្កេតឃើញថាខ្ពស់គ្រាន់បើ នៅទីតាំងស្ថានីយបូមទឹកឆៅដែលមានស្រាប់ ជាងនៅទីតាំងសំណើរសម្រាប់ស្ថានីយបូមទឹកឆៅថ្មី។
- យ៉ុងអាម៉ូញ៉ូម រកឃើញនៅគ្រប់វិភាគ ថាមានកម្រិតទាប។ កម្រិតរកឃើញនៅទីតាំងសំណើរសម្រាប់ស្ថានីយបូមទឹកឆៅថ្មី នៅចន្លោះ 0.01 ដល់ 0.24 mg/L។ ចំណែកកម្រិតនៅស្ថានីយដែលមានស្រាប់ នៅចន្លោះ 0.01 ដល់ 0.61 mg/L។

ភាពល្អក់ក្នុងទឹក មានកម្រិតខ្ពស់ ដែលនាំអោយទឹកមិនអាចផឹកផ្ទាល់បានទេ ប៉ុន្តែអាចផឹកបាន បន្ទាប់ពីឆ្លងកាត់ដំណើរការប្រព្រឹត្តិកម្មតាមបច្ចេកទេសដែលមានប្រើច្រើនបច្ចុប្បន្ន (Conventional Water Treatment Process)។

## តារាង 1-3-3 លទ្ធផលសិក្សាគុណភាពទឹក (1)

| ល.រ | ប៉ារ៉ាម៉ែត្រ | ទីតាំង | Intake 1 (ទីតាំងគ្រោងសម្រាប់ស្ថានីយបូមទឹកឆៅថ្មី) | | | | | | | | | | | ស្តង់ដារទឹកផឹកថ្នាក់ជាតិ | ស្តង់ដារទឹកផឹកជប៉ុន | ការណែនាំរបស់ WHO |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ឆ្នាំ | 2017 | | | | | | 2018 | | | | | | | |
| | | ខែ | 7 | 8 | 9 | 10 | 11 | 12 | 1 | 2 | 3 | 4 | 5 | | | |
| 1 | ប៉េហាះ (pH) | - | 6.76 | 6.14 | 5.64 | 5.87 | 6.76 | 6.56 | 6.96 | 7 | 7.56 | 7.6 | 7.4 | 6.5-8.5 | 5.8-8.6 | – |
| 2 | សីតុណ្ហភាពទឹក | °C | 29 | 31 | 30 | 28 | 28 | 27 | 28.5 | 26 | 31.8 | 31.1 | 32 | – | – | – |
| 3 | ភាពចម្លងអគ្គិសនី (EC) | μs/cm | 55.6 | 79 | 46.2 | 40.1 | 56.5 | 28.9 | 71.9 | 75.8 | 100.4 | 96.7 | 78.6 | – | – | – |
| 4 | សារធាតុរលាយសរុប (TDS) | mg/L | 53 | 76 | 44 | 39 | 54 | 28 | 69 | 73 | 98 | 95 | 77 | <800 | <500 | – |
| 5 | Dissolved Oxygen(DO) | mg/L | 7.21 | 7.05 | 6.64 | 6.3 | 4.49 | 4.78 | 5.98 | 6.5 | 5.95 | 6.3 | 6.2 | – | – | – |
| 6 | ភាពល្អក់ | NTU | 115 | 135 | 50 | 94 | 66 | 70 | 28 | 30 | 26 | 46 | 62 | <5.0 | < 2 | – |
| 7 | ពណ៌ | mg/L Pt | 430 | >500 | 290 | 350 | 150 | 270 | 140 | 155 | 137 | 185 | 297 | <5.0 | <5 | – |
| 8 | សារធាតុមិនរលាយសរុប (TSS) | mg/L | 83 | 97 | 83 | 87 | 46 | 53.3 | 19.5 | 28 | 25.5 | 36.5 | 52 | – | – | – |
| 9 | ភាពរឹងសរុប (as CaCO3) | mg/L | 110 | 110 | 110 | 90 | 92 | 95 | 80 | 120 | 105 | 145 | 150 | <300 | <300 | – |
| 10 | តម្រូវការអុកស៊ីសែនជីវគីមី (BOD)5 | mg/L | 1.8 | 1.88 | 2.05 | 2.6 | 0.09 | 1.02 | 1.6 | 1.2 | 1.2 | 1.25 | 1.6 | – | – | – |
| 11 | ស្យានីត (CN-) | mg/L | ND | ND | ND | ND | ND | ND | ND | ND | ND | ND | ND | <0.02 | <0.01 | – |
| 12 | អ៊ីយ៉ុងក្លរួ ($Cl^-$) | mg/L | 22.6 | 19.3 | 1.11 | 1.91 | 1.19 | 0.44 | 8.5 | 3.4 | 4.6 | 9.3 | 8.5 | <250 | <200 | – |
| 13 | អាម៉ូញាក់ ($NH_3$) | mg/L | 0.01 | 0.01 | 0.01 | 0.07 | 0.23 | 0.16 | 0.05 | 0.18 | 0.18 | 0.24 | 0.24 | <1.5 | – | – |
| 15 | ភ្លុយអរ (F) | mg/L | 0.24 | 0.29 | 0.14 | 0.14 | 0.21 | 0.1 | 0.15 | 0.1 | 0.25 | 0.05 | 0.05 | <1.5 | <0.8 | <1.5 |
| 16 | នីទ្រីត (NO2) | mg/L | ND | ND | 0 | 0 | 0 | 0.008 | 0.03 | 0.01 | 0.09 | 0.03 | 0.03 | <3.0 | <44* | <3 |
| 17 | នីត្រាត ($NO_3^-$) | mg/L | 0.45 | 0.25 | 0.46 | 0.612 | 0.52 | 0.05 | 0.09 | 0.1 | 0.18 | 0.31 | 0.34 | <50 | as $NO_2 + NO_3$ | <50 |
| 18 | អាលុយមីញ៉ូម (Al) | mg/L | 5.09 | 4.9 | 1.86 | 0.45 | 0.22 | 4.62 | 1.02 | 0.86 | 1.03 | 0.31 | 0.74 | <0.2 | <0.2 | – |
| 19 | អាសេនិច (As) | mg/L | ND | ND | ND | ND | ND | <0.005 | <0.005 | <0.005 | <0.005 | <0.005 | <0.005 | <0.05 | <0.01 | <0.01 |
| 20 | បារីយ៉ូម (Ba) | mg/L | 0.0002 | 0.0002 | 0.00953 | 0.106 | 0.006 | 0.02 | 0.02 | 0.02 | 0.02 | 0.03 | 0.03 | <0.7 | – | <1.3 |
| 21 | កាដមីញ៉ូម (Cd) | mg/L | ND | ND | ND | ND | ND | <0.001 | <0.001 | <0.001 | <0.001 | <0.001 | <0.001 | <0.003 | <0.003 | <0.003 |
| 22 | ក្រូមីញ៉ូម (Cr) | mg/L | 0.009 | 0.008 | 0.00908 | 0.016 | ND | <0.005 | <0.005 | <0.005 | <0.005 | <0.005 | <0.005 | <0.05 | <0.05 as $Cr^{6+}$ | <0.05 |
| 23 | ដែក (Fe) | mg/L | 0.51 | 0.21 | 0.102 | 0.05 | 0.05 | 2.24 | 1.36 | 1.07 | 1.15 | 1.48 | 1.46 | <0.3 | <0.3 | – |
| 24 | សំណ (Pb) | mg/L | 0.001 | 0.003 | 0.00059 | 0.003 | ND | <0.005 | <0.005 | <0.005 | <0.005 | <0.005 | <0.005 | <0.01 | <0.01 | <0.01 |
| 25 | ម៉ង់ហ្គាណែស (Mn) | mg/L | 0.05 | 0.1 | 0.02762 | 0.048 | 0.02 | 0.01 | 0.08 | 0.06 | 0.05 | 0.1 | 0.08 | <0.3 | <0.05 | – |
| 26 | បារត (Hg) | mg/L | ND | ND | ND | ND | ND | <0.0005 | <0.0005 | <0.0005 | <0.0005 | <0.0005 | <0.0005 | <0.001 | <0.0005 | <0.006 |
| 27 | នីកែល (Ni) | mg/L | 0.003 | 0.004 | 0.0034 | 0.006 | ND | <0.005 | <0.005 | <0.005 | <0.005 | <0.005 | <0.005 | <0.02 | – | <0.07 |
| 28 | សេលេញ៉ូម (Se) | mg/L | — | — | — | — | — | <0.002 | <0.002 | <0.002 | <0.002 | <0.002 | <0.002 | <0.01 | <0.01 | <0.04 |
| 29 | គូលីហ្វមសរុប | MPN/100ml | $2.1X10^3$ | $1.5X10^3$ | $2.1X10^3$ | $2.1X10^3$ | 92 | $1.5X10^3$ | $1.5X10^3$ | $2.0X10^2$ | $4.3X10^2$ | $1.5X10^2$ | $1.5X10^3$ | 0 | – | – |
| 30 | អ៊ីកូឡាយ | MPN/100ml | $2.8X10^2$ | $2.9X10^2$ | $2.8X10^2$ | 61 | 36 | 36 | $1.5X10^2$ | 61 | 92 | 61 | $1.5X10^2$ | 0 | 0 | 0 |

ប្រភព៖ ក្រុមចុះសិក្សា

# តារាង 1-3-4 លទ្ធផលសិក្សាគុណភាពទឹក (2)

| ល.រ | ប៉ារ៉ាម៉ែត្រ | ទីតាំង | Intake 2 (ទីតាំងស្ថានីយបូមទឹកនៅបុក្ខប្បទ្ម) | | | | | | | | | | | ស្តង់ដារទឹកផឹកថ្នាក់ជាតិ | ស្តង់ដារទឹកផឹកជប៉ុន | ការណែនាំរបស់ WHO |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ឆ្នាំ | 2017 | | | | | | 2018 | | | | | | | |
| | | ខែ | 7 | 8 | 9 | 10 | 11 | 12 | 1 | 2 | 3 | 4 | 5 | | | |
| 1 | ប៉េហាះ (pH) | - | 6.64 | 6.19 | 5.74 | 5.84 | 6.48 | 6.52 | 7.01 | 7.2 | 7.43 | 7.2 | 7.2 | 6.5-8.5 | 5.8-8.6 | – |
| 2 | សីតុណ្ហភាពទឹក | °C | 29.5 | 31 | 31 | 28 | 27.5 | 28 | 29 | 26.8 | 32.5 | 30.4 | 30.4 | – | – | – |
| 3 | ភាពចម្លងអគ្គិសនី (EC) | µs/cm | 55.8 | 56 | 44.8 | 37.7 | 58 | 47.9 | 69.3 | 92.2 | 84.6 | 85 | 102.7 | – | – | – |
| 4 | សារធាតុរលាយសរុប (TDS) | mg/L | 53 | 58 | 43 | 36 | 56 | 46 | 67 | 89 | 83 | 83 | 101 | <800 | <500 | – |
| 5 | Dissolved Oxygen(DO) | mg/L | 6.03 | 6.53 | 6.95 | 5.68 | 5.4 | 5 | 5.2 | 6.5 | 4.5 | 5.8 | 5.8 | – | – | – |
| 6 | ភាពល្អក់ | NTU | 115 | 110 | 60 | 86 | 52 | 70 | 32 | 26 | 26 | 48 | 54 | <5.0 | < 2 | – |
| 7 | ពណ៌ | mg/L Pt | 400 | 500 | 295 | 360 | 205 | 320 | 175 | 165 | 180 | 160 | 290 | <5.0 | <5 | – |
| 8 | សារធាតុមិនរលាយសរុប (TSS) | mg/L | 79 | 82 | 79 | 75 | 54 | 78.89 | 30 | 31.5 | 24 | 34 | 44 | – | – | – |
| 9 | ភាពរឹងសរុប (as CaCO3) | mg/L | 135 | 115 | 135 | 70 | 84 | 95 | 80 | 135 | 115 | 130 | 165 | <300 | <300 | – |
| 10 | តម្រូវការអុកស៊ីសែនជីវគីមី (BOD)5 | mg/L | 1.4 | 1.55 | 1.4 | 1.2 | 1.05 | 1.15 | 1.2 | 1 | 1.4 | 1.62 | 2 | – | – | – |
| 11 | ស្យានីត (CN-) | mg/L | ND | ND | ND | ND | ND | ND | ND | ND | ND | DN | DN | <0.02 | <0.01 | – |
| 12 | អ៊ីយ៉ុងក្លរួ ($Cl^-$) | mg/L | 22.95 | 13.78 | 0.97 | 1.03 | 1.28 | 0.29 | 9 | 6.5 | 7.4 | 9.3 | 17.7 | <250 | <200 | – |
| 13 | អាម៉ូញាក់ ($NH_3$) | mg/L | 0.008 | 0.007 | 0.008 | 0.19 | 0.3 | 0.23 | 0.05 | 0.18 | 0.22 | 0.61 | 0.37 | <1.5 | – | – |
| 15 | ភ្លុយអរ (F) | mg/L | 0.1 | 0.11 | 0.13 | 0.14 | 0.21 | 0.05 | 0 | 0.15 | 0.05 | 0.1 | 0.02 | <1.5 | <0.8 | <1.5 |
| 16 | នីទ្រីត (NO2) | mg/L | ND | ND | 0 | 0 | 0 | 0 | 0.03 | 0.02 | 0.08 | 0.09 | 0.21 | <3.0 | <44* | <3 |
| 17 | នីត្រាត ($NO_3^-$) | mg/L | 0.27 | 0.12 | 0.49 | 0.54 | 0.66 | 0.02 | 0.11 | 0.02 | 0.35 | 0.44 | 0.66 | <50 | as $NO_2 + NO_3$ | <50 |
| 18 | អាលុយមីញ៉ូម (Al) | mg/L | 4.39 | 3.6 | 2.357 | 0.92 | 0.18 | 4.97 | 1.44 | 1.14 | 2.17 | 0.31 | 0.73 | <0.2 | <0.2 | – |
| 19 | អាសេនិច (As) | mg/L | ND | 0.01 | ND | ND | ND | <0.005 | <0.005 | <0.005 | <0.005 | <0.005 | <0.005 | <0.05 | <0.01 | <0.01 |
| 20 | បារីយ៉ូម (Ba) | mg/L | 0.0003 | ND | 0.00995 | 0.15 | 0.006 | 0.02 | 0.02 | 0.03 | 0.02 | 0.01 | 0.02 | <0.7 | – | <1.3 |
| 21 | កាដមីញ៉ូម (Cd) | mg/L | ND | ND | ND | ND | ND | <0.001 | <0.001 | <0.001 | <0.001 | <0.001 | <0.001 | <0.003 | <0.003 | <0.003 |
| 22 | ក្រូមីញ៉ូម (Cr) | mg/L | 0.009 | 0.007 | 0.00969 | 0.018 | ND | <0.005 | <0.005 | <0.005 | <0.005 | <0.005 | <0.005 | <0.05 | <0.05 as $Cr^{6+}$ | <0.05 |
| 23 | ដែក (Fe) | mg/L | 0.19 | 0.15 | 0.11097 | 0.07 | 0.051 | 2.27 | 1.58 | 1.29 | 1.81 | 0.74 | 1.46 | <0.3 | <0.3 | – |
| 24 | សំណ (Pb) | mg/L | 0.001 | 0.002 | 0.00319 | 0.003 | ND | <0.005 | <0.005 | <0.005 | <0.005 | <0.005 | <0.005 | <0.01 | <0.01 | <0.01 |
| 25 | ម៉ង់ហ្គាណែស (Mn) | mg/L | 0.03 | 0.08 | 0.02697 | 0.06 | 0.024 | 0.01 | 0.06 | 0.07 | 0.06 | 0.06 | 0.08 | <0.3 | <0.05 | – |
| 26 | បារ៉ត (Hg) | mg/L | ND | ND | ND | ND | ND | <0.0005 | <0.0005 | <0.0005 | <0.0005 | <0.0005 | <0.0005 | <0.001 | <0.0005 | <0.006 |
| 27 | នីកែល (Ni) | mg/L | 0.002 | 0.002 | 0.00534 | 0.007 | ND | <0.005 | <0.005 | <0.005 | <0.005 | <0.005 | <0.005 | <0.02 | – | <0.07 |
| 28 | សេលេញ៉ូម (Se) | mg/L | — | — | — | — | — | <0.002 | <0.002 | <0.002 | <0.002 | <0.002 | <0.002 | <0.01 | <0.01 | <0.04 |
| 29 | កូលីហ្វមសរុប | MPN/100ml | $1.1X10^4$ | $4.6X10^3$ | $1.1X10^4$ | $1.1X10^4$ | $1.1X10^4$ | $1.1X10^4$ | $4.3X10^3$ | $2.8X10^2$ | $1.1X10^4$ | $9.3X10^2$ | $2.1X10^3$ | 0 | – | – |
| 30 | អ៊ីកូឡាយ | MPN/100ml | $3.6X10^2$ | $3.6X10^2$ | $3.6X10^2$ | 72 | $4.3X10^2$ | 74 | 36 | 74 | $1.5X10^3$ | 72 | $4.3X10^2$ | 0 | 0 | 0 |

* ស្តង់ដារជប៉ុន កំណត់ផលបូកនៃអាសូតនីត្រាត និងអាសូតនីទ្រីត ជា 10mg/l។ នេះជាតម្លៃដែលបានបម្លែងជាក់ហាប់នីត្រាត។

ប្រភព៖ ក្រុមចុះសិក្សា

ទឹកស្ទឹងពោធិ៍សាត់ ត្រូវគេប្រើប្រាស់ទូទៅ សម្រាប់ការងារកសិកម្ម ប៉ុន្តែបរិមាណសម្រាប់ការផ្គត់ផ្គង់ទឹកស្អាត និងសម្រាប់ជារទឹកទាបបំផុតក្នុងស្ទឹង ក៏ត្រូវគេជានាផងដែរ ទោះមានការអភិវឌ្ឍន៍ប្រព័ន្ធស្រោចស្រពថ្មីក៏ដោយ។ ហើយក៏មានកាបញ្ជាក់ពីក្រសួងធនធានទឹក និងឧតុនិយមផងដែរ នូវការអនុញ្ញាតអោយដកទឹកពីស្ទឹងពោធិ៍សាត់ មកប្រើប្រាស់ដោយគ្មានបញ្ហា ដូចមានក្នុងលិខិតចេញនៅថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ២០១៧។ នេះបញ្ជាក់ថា វាគ្មានបញ្ហាទេ ក្នុងការបូមទឹកពីស្ទឹងពោធិ៍សាត់។

### 1-3-2-6 សំឡេង និងរំញ័រ

តំបន់គម្រោង មិនមែនជាតំបន់ឧស្សាហកម្ម។ មិនមានចរាចរណ៍ច្រើនទេ លើកលែងតាមផ្លូវជាតិ។ ដូច្នេះ ប្រភពសំឡេង និងរំញ័រ មិនមានច្រើនឡើយ។ ម្យ៉ាងវិញទៀត ចំនួនយានយន្តចុះបញ្ជី មានការកើនឡើងយ៉ាងលឿន ក្នុងអត្រា ១៤%ក្នុងឆ្នាំ២០១៥ ដែលនាំឲ្យអត្រាសំឡេងក្នុងកម្រិតមួយ កើតមានតាមបណ្តោយផ្លូវមេ។ មិនមានកំណត់ត្រាតាមដានកម្រិតសំឡេងណាមួយទេ ដូច្នេះ ក្រុមសិក្សា បានរៀបចំស្រាវជ្រាវសំឡេង និងរំញ័រ នាថ្ងៃទី ២ និងទី ៣ ខែកុម្ភៈ ឆ្នាំ២០១៨។ លទ្ធផល មានសង្ខេប ក្នុងតារាងខាងក្រោម។ ទីតាំង 1 (Site 1) វាស់នៅក្បែរទីតាំងគ្រោងធ្វើស្ថានីយបូមទឹកឆៅ និងទីតាំង 2 (Site 2) វាស់នៅក្បែរ ទីតាំងគ្រោងធ្វើរោងចក្រប្រព្រឹត្តិកម្មទឹក។ ការវាស់ ធ្វើឡើងជាប់គ្នា ២៤ម៉ោង។ តារាង បង្ហាញកម្រិតសំឡេង (រំញ័រ) និងកម្រិតអតិបរិមា បង្ហាញក្នុងរង្វង់ក្រចក។ កម្រិតអតិបរិមានេះ ត្រូវបានរាយការណ៍ថាបានវាស់នៅពេលមានភ្លៀងខ្លាំង។

**តារាង 1-3-5 លទ្ធផលវាស់សំឡេង និងរំញ័រ**

| | ទីតាំង 1 | ទីតាំង 2 | ស្តង់ដារធៀប | | |
|---|---|---|---|---|---|
| សំឡេង（6：00〜18：00) | 54.6 (118.4) | 49.7 (101.5) | II | III | ស្តង់ដារសំឡេងកម្ពុជា |
| | | | 60 | 70 | II : តំបន់លំនៅដ្ឋាន |
| សំឡេង（18：00〜22：00) | 46.5 (54.9) | 46.1 (54.9) | 50 | 65 | III : តំបន់ពាណិជ្ជកម្ម |
| សំឡេង（22：00〜6：00) | 42.7 (49.9) | 42.3 (38.3) | 45 | 50 | |
| រំញ័រ（6：00〜18：00) | 27.3 (32.6) | 12.9 (42.5) | 65 | | Request limit of road traffic vibration in Japan (តំបន់ប្រភេទ 1) |
| រំញ័រ（18：00〜6：00) | 25.9 (42.5) | 12.5 (40.7) | 60 | | |

ប្រភព៖ ក្រុមចុះសិក្សា

ង់ដារសំឡេងកម្ពុជា មានប្រភេទ ដូចជា ប្រភេទ I សម្រាប់តំបន់ស្ងាត់, ប្រភេទ II សម្រាប់តំបន់លំនៅដ្ឋាន, ប្រភេទ III សម្រាប់តំបន់ពាណិជ្ជកម្ម សេវាកម្ម និងចម្រុះ និងប្រភេទ IV សម្រាប់ឧស្សាហកម្មធន់ស្រាល លាយចម្រុះនៅក្នុងតំបន់លំនៅដ្ឋាន។ មន្ទីរបរិស្ថានពោធិ៍សាត់ បានណែនាំថាតំបន់គម្រោងស្ថិតក្នុងប្រភេទ III។ លទ្ធផលសិក្សា បង្ហាញថាកម្រិតសំឡេង ឆ្លើយតបនឹងស្តង់ដារប្រភេទ II និងប្រភេទ III ផងដែរ។

ដោយសារមិនមានស្តង់ដារ ឬការណែនាំកម្ពុជា ចំពោះកម្រិតរំញ័រ គេយក លទ្ធផលកម្រិតរំញ័រ មកប្រៀបធៀបជាមួយ “Request limit of road traffic vibration” ក្នុងច្បាប់រំញ័រជប៉ុន។ ប្រភេទ 1 ជាតំបន់រក្សា

ភាពស្ងៀមស្ងាត់ ដើម្បីរក្សាបរិស្ថានល្អ និងតំបន់លំនៅដ្ឋាន។ ឃើញថា ទាំងសំឡេង និងរំញ័រដែលបានវាស់ មានកម្រិតទាប អាចនិយាយបានថា បរិស្ថានក្នុងន័យនេះ មានលក្ខណៈល្អ។

### 1-3-2-7 សន្ទស្សន៍សេដ្ឋកិច្ច

ឧស្សាហកម្មចម្បងនៅពោធិ៍សាត់ គឺកសិកម្ម។ ដីសម្រាប់កសិកម្មស្រូវ មានផ្ទៃធំជាងគេបំផុត។ លើសពីនេះ មានសកម្មភាពកសិកម្មផ្សេងៗទៀត ដូចជា ពោត ដំឡូងឈើ (cassava) សណ្ដែកនិងបន្លែ ការចិញ្ចឹមសត្វ និងការនេសាទតាមបឹងទន្លេសាប។

រូបខាងក្រោម បង្ហាញអំពី ស្រុក និងឃុំទាំងឡាយ[5] ក្នុងតំបន់គម្រោង។ តំបន់ដែលមានពណ៌បៃតង ជាឃុំគោលដៅ។




**រូប 1-3-3 តំបន់គ្រប់គ្រងគោលដៅ**

មុខរបរក្នុងតំបន់គម្រោង តាមស្រុកនីមួយៗ មានបង្ហាញក្នុងតារាងខាងក្រោម។ ក្រុងពោធិ៍សាត់ ជាទីប្រជុំជន ដែលអត្រាមានការងារធ្វើ ខ្ពស់ជាងស្រុកដទៃ។ ទោះយ៉ាងណា ក្នុងក្រុងពោធិ៍សាត់ កសិករមានជាងពាក់កណ្ដាល ជាហេតុនាំអោយ អ្នកទទួលផលពីគម្រោងភាគច្រើន គឺកសិករ។

**តារាង 1-3-6 មុខរបរ (%)**

| ខេត្ត/ស្រុក/ក្រុង | កសិកម្ម | សិប្បកម្ម | សេវាកម្ម |
|---|---|---|---|
| ខេត្តពោធិ៍សាត់ | 85.4 | 0.4 | 12.4 |
| បាកាន | 90.3 | 0.2 | 7.6 |
| កណ្ដៀង | 86.2 | 0.1 | 13.3 |
| ក្រុងពោធិ៍សាត់ | 57.0 | 2.0 | 37.5 |

ប្រភព៖ NCDD, Commune Database Online

[5] ប្រទេសកម្ពុជា មាន២៥ រាជធានីខេត្ត ដោយគិតទាំងតំបន់គ្រប់គ្រងពិសេស នៃរាជធានីភ្នំពេញ។ ខេត្តត្រូវគេបែងចែកជាស្រុក។ រួចស្រុកត្រូវគេបែងចែកបន្ត ជាឃុំ។

### 1-3-2-8 ការប្រើប្រាស់ដី

រូបភាពខាងក្រោម បង្ហាញអំពីការប្រើប្រាស់ដី ក្នុងខេត្តពោធិ៍សាត់។ ចំណែកឯតារាង បង្ហាញអំពីទំហំ និងគោលបំណងនៃការប្រើប្រាស់ដី។




**រូប 1-3-4 ការប្រើប្រាស់ដីទៅតាមប្រភេទ**

ប្រភព៖ ផ្អែកលើ Pursat Data Book 2009

**តារាង 1-3-7 ក្រឡាផ្ទៃនៃការប្រើប្រាស់ដី**

| ប្រភេទដី | ក្រឡាផ្ទៃ (ហត) | % |
|---|---|---|
| ដីតាំងលំនៅ Settlement | 7,359.62 | 0.6 |
| វាលស្រែ Paddy Field | 154,373.54 | 13.3 |
| ដីកសិកម្ម Farming Land | 10,035.53 | 0.9 |
| ព្រៃស្រោង Evergreen Forest | 463,925.44 | 40.0 |
| ព្រៃល្បោះ Deciduous Forest | 198,603.23 | 17.1 |
| ព្រៃចម្រុះ Mixed Forest | 81,364.82 | 7.0 |
| ព្រៃប្រភេទផ្សេង Other Forest | 123,520.39 | 10.7 |
| វាលស្មៅ Grassland | 23,158.65 | 2.0 |

| | | |
|---|---|---|
| ព្រៃគុម្ពោត Scrub | 31,800.37 | 2.7 |
| ដីគ្មានដីជាតិ Barren Land | 57,772.66 | 5.0 |
| ទឹក Water | 6,244.30 | 0.5 |

ប្រភព៖ ផ្អែកលើ Pursat Data Book 2009

ដីក្នុងខេត្តពោធិ៍សាត់ចំនួន 75% គ្របដណ្តប់ ដោយព្រៃ។ ផែនទី បង្ហាញយ៉ាងច្បាស់ថា តំបន់ព្រៃស្ថិតនៅភាគនិរតី។ ចំណែកភាគខាងឥសាន្ត រួមទាំងតំបន់គម្រោងផង គ្របដណ្តប់ដោយ ដីកសិកម្ម ទីប្រជុំជន និងតំបន់លំនៅដ្ឋាន។ បីភាគបួន នៃដីកសិកម្ម ត្រូវគេប្រើប្រាស់សម្រាប់ធ្វើស្រែ និងជាទូទៅ តែមួយរដូវ។

### 1-3-2-9 កាកសំណល់រឹង

សំណល់ពីការងារសាងសង់ អាចទុកនៅក្នុងដី ដែលជារបស់ម្ចាស់គម្រោង (project proponent) ប្រសិនវាមិនគ្រោះថ្នាក់។ មិនអញ្ចឹងទេ កាកសំណល់នោះ ត្រូវវិភាគ ដោយក្រសួងបរិស្ថាន។

បច្ចុប្បន្ន ភក់ដែលកើតចេញពីដំណើរការប្រព្រឹត្តិកម្មទឹកស្អាត របស់រដ្ឋាករទឹកពោធិ៍សាត់ បង្ហូរចូលទៅក្នុងស្ទឹងពោធិ៍សាត់ ដោយមានកិច្ចសន្យារវាងរដ្ឋាករទឹក និងមន្ទីរបរិស្ថាន។ ករណីភក់ស្ងួត អាចចាត់ទុកដូចជាសំណល់ពីការសាងសង់ដែលមិនមែនគ្រោះថ្នាក់ដែរ ប្រសិនវាមិនមានសារធាតុគ្រោះថ្នាក់។ ភក់ ជារបាយនៃភាគល្អក់ក្នុងទឹក និងសារធាតុគីមីសម្រាប់បន្សុទ្ធទឹក ដូច្នេះ គេមិនរំពឹងថាមានសារធាតុគ្រោះថ្នាក់លាយឡំឡើយ។ ក្រសួងឧស្សាហកម្ម បានបញ្ជាក់ថា ម្ចាស់ដីធ្លីទាំងឡាយ ត្រូវការភក់ទាំងនេះ ដើម្បីបំពេញដីរបស់ពួកគាត់កុំអោយលិចទឹក ដូច្នេះការចោលភក់ មិនជាបញ្ហាចោទឡើយ។

### 1-3-2-10 ភាពក្រីក្រ

ក្រសួងផែនកា បានចុះស្រាវជ្រាវទូទាំងប្រទេស ដើម្បីកំណត់អត្តសញ្ញាណអ្នកមានចំណូលទាប ក្នុងគោលបំណងកាត់បន្ថយអត្រាភាពក្រីក្រ ដែលគាំទ្រដោយ German Federal Ministry for Economic Cooperation and Development (BMZ), the Australian Department of Foreign Affairs និង Trade and Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH។ កម្មវិធីនេះ បានកំណត់ភាពក្រីក្រជា ពីរប្រភេទ គឺ កម្រិត ១ (ចំណូលទាបខ្លាំង) និងកម្រិត ២ (ចំណូលទាប) និងបានផ្តល់កាតសំគាល់ភាពក្រីក្រ ដើម្បីអោយពួកគាត់ទទួលបានការគាំទ្រ និងអត្ថប្រយោជន៍ បានត្រឹមត្រូវ។ ការចុះស្រាវជ្រាវចុងក្រោយបំផុត ក្នុងខេត្តពោធិ៍សាត់ បានធ្វើឡើងក្នុងឆ្នាំ ២០១៣។
តារាងខាងក្រោម បង្ហាញពីស្ថានភាពក្រីក្រ ក្នុងតំបន់គម្រោង។

**តារាង 1-3-8 ចំនួនលំនៅដ្ឋានក្រីក្រ ក្នុងតំបន់គម្រោង**

| ស្រុក/ក្រុង | ឃុំ/សង្កាត់ | ក្រកម្រិត ១ | | ក្រកម្រិត ២ | | សរុប |
|---|---|---|---|---|---|---|
| | | ចំនួន | % | ចំនួន | % | ចំនួន |
| បាកាន | ស្នាមព្រះ | 499 | 12.8% | 521 | 13.4% | 1020 |
| កណ្តៀង | អន្លង់វិល | 230 | 19.1% | 132 | 11.0% | 362 |
| | កណ្តៀង | 207 | 14.0% | 299 | 20.3% | 506 |

| ស្រុក/ក្រុង | ឃុំ/សង្កាត់ | ក្រកម្រិត ១ | | ក្រកម្រិត ២ | | សរុប |
|---|---|---|---|---|---|---|
| | | ចំនួន | % | ចំនួន | % | ចំនួន |
| | ស្វាយលួង | 151 | 11.4% | 209 | 15.8% | 360 |
| | វាល | 174 | 15.2% | 198 | 17.3% | 372 |
| | កោះជុំ | 154 | 9.2% | 330 | 19.8% | 484 |
| ក្រុងពោធិ៍សាត់ | ចម្រើនផល | 291 | 21.5% | 223 | 16.5% | 514 |
| | លលក ស | 116 | 6.1% | 170 | 8.9% | 286 |
| | ផ្ទះព្រៃ | 44 | 2.5% | 212 | 12.3% | 256 |
| | ព្រៃញី | 106 | 9.7% | 133 | 12.1% | 239 |
| | រលាប | 182 | 6.3% | 359 | 12.4% | 541 |
| | ស្វាយអាត់ | 102 | 10.2% | 187 | 18.7% | 289 |
| | បន្ទាយដី | 102 | 8.0% | 206 | 16.1% | 308 |
| | សរុប | 2,358 | | 3,179 | | 5,537 |

ប្រភព៖ ក្រសួងផែនការ, ប្រព័ន្ធទិន្នន័យនៃកម្មវិធីកំណត់អត្តសញ្ញាណក្រីក្រ

ចំនួនលំនៅដ្ឋានក្រីក្រ គឺចាប់ពី ១៥%ទៅ ៣៥%ក្នុងតំបន់នេះ។

### 1-3-2-11 ជនជាតិភាគតិច

ជាតិសាសន៍នៅកម្ពុជា មានខ្មែរ 97.6%ចាម 1.2%ចិន 0.1%វៀតណាម 0.1%និងសាសន៍ដទៃទៀតរួមគ្នា 0.9%(យោងតាមការប៉ាន់ស្មានក្នុង CIA World Fact Book)។ តាមរយៈពត៌មានពីមន្ទីរបរិស្ថាន និងសាលាក្រុង មិនមានជនជាតិភាគតិច រស់នៅក្នុងតំបន់គម្រោងឡើយ។

### 1-3-2-12 ការអប់រំ និងអត្រាចេះអាន និងសរសេរ

តារាងខាងក្រោម បង្ហាញអត្រាចេះអាននិងសរសេរ អត្រាសិស្សរៀនថ្នាក់បឋមសិក្សា ក្នុងខេត្តពោធិ៍សាត់ និងតំបន់គម្រោង។

**តារាង 1-3-9 អត្រាចេះអាន និងសរសេរ និងអត្រារៀនថ្នាក់បឋមសិក្សា (%)**

| ស្រុក | អត្រាចេះសរសេរនិងអាន(15~60 ឆ្នាំ) | អត្រារៀនថ្នាក់បឋមសិក្សា |
|---|---|---|
| ខេត្តពោធិ៍សាត់ | 86.4 | 84.0 |
| ស្រុកបាកាន | 88.0 | 87.0 |
| ស្រុកកណ្ដៀង | 82.9 | 78.7 |
| ក្រុងពោធិ៍សាត់ | 92.3 | 90.2 |

ប្រភព៖ គ.ជ.អ.ប. ប្រព័ន្ធទិន្នន័យឃុំតាមអ៊ីនធឺណិត

ក្រុងពោធិ៍សាត់ ដែលជាតំបន់ប្រជុំជន មានអត្រាចេះអាននិងសរសេរ និងរៀនថ្នាក់បឋមសិក្សា ខ្ពស់។ ដូចគ្នានេះដែរ រាជធានីភ្នំពេញ ដែលជាទីក្រុងធំជាងគេ មានអត្រាចេះអាននិងសរសេរ ខ្ពង់ 98% តារាងបន្ទាប់ បង្ហាញអត្រាចេះអានសរសេរ ទៅតាមជំនាន់ ដែលក្នុងនោះ យើងឃើញថា អត្រាចេះអានសរសេរក្មេងៗ ខ្ពស់ជាងជំនាន់ចាស់ៗ។

**តារាង 1-3-10 អត្រាចេះអានសរសេរ ក្នុងខេត្តពោធិ៍សាត់ តាមជំនាន់ (%)**

| | 15~60 ឆ្នាំ សរុប | 15~60 ឆ្នាំ ស្រី | 15~17 ឆ្នាំ | 18~24 ឆ្នាំ | 25~60 ឆ្នាំ |
|---|---|---|---|---|---|
| អត្រាចេះអានសរសេរ (%) | 86.4 | 85.9 | 92.5 | 90.4 | 83.3 |

ប្រភព៖ គ.ជ.អ.ប. ប្រព័ន្ធទិន្នន័យឃុំតាមអ៊ីនធ័រណេត

យោងតាមការចុះសិក្សាសង្គមផ្ទាល់ កម្រិតវប្បធម៌របស់មេគ្រួសារ គឺ 91%បានចូលសាលា និង 10%រៀនដល់ថ្នាក់វិទ្យាល័យ និងខ្ពស់ជាងនេះទៀត។

### 1-3-2-13 ស្ថានភាពសុខភាព និងអនាម័យ

ទិន្នន័យសុភាព និងអនាម័យ ដែលបានមកពីការចុះសិក្សាសង្គម មានបង្ហាញក្នុងតារាងខាងក្រោម។ សំណាកសម្រាប់សិក្សា ចែកជាពីរក្រុម គឺក្រុមដែលទទួលទឹកស្អាតពីរដ្ឋាករទឹកពោធិ៍សាត់ (Connected HHs) និងក្រុមដែលរស់នៅក្រៅតំបន់ផ្គត់ផ្គង់ទឹក (Non-connected HHs)។

**តារាង 1-3-11 ស្ថានភាពសុខភាព និងអនាម័យ ក្នុងតំបន់គម្រោង**

| | សរុប | Connected HHs | Non-connected HHs |
|---|---|---|---|
| មានបង្គន់ (%) | 86 | 98 | 75 |
| ឈឺដោយសារមេរោគក្នុងទឹក (បីឆ្នាំចុងក្រោយ) (%) | 6 | 1 | 12 |

ប្រភព៖ លទ្ធផលសិក្សាសង្គម

មានបង្គន់ប្រើប្រាស់ មានអត្រារៀងខ្ពស់ ក្នុងប្រទេសកម្ពុជា។ ចំនួនឈឺ ដោយសារមេរោគក្នុងទឹក មានអត្រាទាបមែនទែនចំពោះអ្នកទទួលបានសេវាទឹកស្អាត ធៀបទៅនឹងអ្នកមិនបានទទួលសេវាទឹកស្អាត។

យោងតាមប្រព័ន្ធទិន្នន័យរបស់ គ.ជ.អ.ប. (គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ) អត្រាកុមារស្លាប់ (អាយុក្រោម 5 ឆ្នាំ ក្នុង 1000 កំណើត) គឺ 26.7 ក្នុងខេត្តពោធិ៍សាត់ និង 8.1 ក្នុងក្រុងពោធិ៍សាត់។ ស្ថានភាពសុខភាព និងអនាម័យក្នុងទីប្រជុំជន ដូចជាគ្រាន់បើជាងនៅតំបន់ដាច់ស្រយាល។

### 1-3-3 ប្រព័ន្ធ និងស្ថាប័ន សិក្សាហេតុប៉ះពាល់បរិស្ថាន និងសង្គម នៅកម្ពុជា

#### 1-3-3-1 ប្រព័ន្ធ និងស្ថាប័ន សិក្សាហេតុប៉ះពាល់បរិស្ថាន និងសង្គម

ភ្នាក់ងារកម្ពុជា ទទួលបន្ទុកការងារបរិស្ថាន គឺក្រសួងបរិស្ថាន MoE)។ នៅក្រោមរដ្ឋមន្ត្រី ក្រសួងបរិស្ថាន មានអគ្គនាយកដ្ឋាន ៥ ធ្វើការងារទៅតាមទំនួលខុសត្រូវរាងៗខ្លួន។




ក្នុងខេត្តនីមួយៗ មានមន្ទីរបរិស្ថានខេត្ត (DOE) ដែលទទួលបន្ទុកការងារបរិស្ថានតាមខេត្តនីមួយៗ។ ច្បាប់ទាក់ទងបរិស្ថាន សង្ខេបដូចខាងក្រោម។

**តារាង 1-3-12 ច្បាប់ និងបញ្ញត្តិបរិស្ថាន កម្ពុជា**

| ឈ្មោះ | គោលបំណង |
|---|---|
| រដ្ឋធម្មនុញ្ញ (1993) | មាត្រា 59 ត្រូវគេចែង ដើម្បីអភិរក្ស និងការពារបរិស្ថាន និងស្ថានភាពធម្មជាតិ ដោយរៀបចំផែនការ និងការគ្រប់គ្រង យ៉ាងជាក់លាក់។ |
| ព្រះរាជក្រមស្តីពីការបង្កើតតំបន់ការពារ (1993) | ព្រះរាជក្រមនេះ កំណត់តំបន់សម្រាប់ការពារ គ្រប់គ្រង និងទទួលខុសត្រូវ។ |
| ច្បាប់បង្កើតក្រសួងបរិស្ថាន (1996) | ច្បាប់នេះ ចែងអំពីការបង្កើតក្រសួងបរិស្ថាន និងភារកិច្ច |
| ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ (1996) | ច្បាប់នេះ គឺដើម្បីការពារ និងលើកស្ទួយគុណភាពបរិស្ថាន និងសុខភាពសាធារណៈ។ |
| ច្បាប់ស្តីពីបេតិកភណ្ឌវប្បធម៌ (1996) | ច្បាប់នេះ គឺដើម្បីការពារបេតិកភណ្ឌវប្បធម៌ធម្មជាតិ និងទ្រព្យសម្បត្តិវប្បធម៌។ |
| ច្បាប់ស្តីពីតំបន់ដីសើមមានសារៈសំខាន់ជាអន្តរជាតិ (1996) | ច្បាប់នេះ គឺដើម្បីការពារតំបន់ដីសើម ជាពិសេសចំពោះអនុសញ្ញារ៉ាមសារ |
| អនុក្រឹត្យស្តីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (1999) | អនុក្រឹត្យនេះ ពន្យល់យ៉ាងច្បាស់អំពី ការវាយតម្លៃបរិស្ថាន ការស្នើសុំនីតិវិធី ។ល។ |
| អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលទឹក (1999) | អនុក្រឹត្យនេះ កំណត់ការគ្រប់គ្រងគុណភាពទឹកដែលនៅជុំវិញ បញ្ញត្តិនៃការបញ្ចេញសំណល់រាវ ។ល។ |
| អនុក្រឹត្យស្តីពីការគ្រប់គ្រងសំណល់រឹង (1999) | អនុក្រឹត្យនេះ កំណត់ពីការចាក់ចោលសំណល់រឹងឲ្យបានត្រឹមត្រូវ និងបញ្ហាដែលពាក់ព័ន្ធ។ |
| អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំឡេង (2000) | អនុក្រឹត្យនេះ កំណត់ការគ្រប់គ្រងគុណភាពខ្យល់ជុំវិញ ការត្រួតពិនិត្យសំឡេង រំញ័រ និងការបញ្ចេញឧស្ម័ន។ |
| ច្បាប់ស្តីពីព្រៃឈើ (2002) | ច្បាប់នេះ គឺដើម្បីការពារព្រៃឈើ និងសត្វព្រៃ |
| ច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹក (2007) | ច្បាប់នេះ បញ្ជាក់អំពីការគ្រប់គ្រងធនធានទឹក និងស្ថាប័នទទួលបន្ទុក។ |
| ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ (2008) | ច្បាប់នេះ និយាយអំពីគោលការណ៍គ្រប់គ្រង អភិរក្ស និងអភិវឌ្ឍតំបន់ការពារធម្មជាតិ។ |
| ប្រកាសស្តីពីការចុះបញ្ជីក្រុមហ៊ុនទីប្រឹក្សាសម្រាប់ការសិក្សា និងរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម (2014) | ប្រកាសនេះ បញ្ជាក់អំពីភាពចាំបាច់នៃការចុះបញ្ជីរបស់ក្រុមហ៊ុនទីប្រឹក្សា ក្នុងការសិក្សា និងរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ |
| អនុក្រឹត្យស្តីពីការបង្កើតរបៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិ (2017) | អនុក្រឹត្យនេះ ប្រកាសអំពីរបៀបអភិរក្ស ដើម្បីការពារបរិស្ថានធម្មជាតិ។ |

ប្រភព៖ ក្រុមសិក្សា JICA ដោយយោងលើច្បាប់ និងបញ្ញត្តិកម្ពុជា

## 1-3-3-2 ស្តង់ដារបរិស្ថាន

ស្តង់ដារបរិស្ថាន និងការបញ្ចេញជាតិពុល មានសង្ខេបក្នុងតារាងខាងក្រោម។

## តារាង 1-3-13 ស្តង់ដារបរិស្ថាន

| គោលដៅ | | ប៉ារ៉ាម៉ែត្រ | សំគាល់ | ប្រភព |
|---|---|---|---|---|
| ខ្យល់ | គុណភាពខ្យល់ជុំវិញ | CO, NO2, SO2, O3, Pb, TSP | | អនុក្រិតស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំឡេង |
| | ខ្យល់ពុលជុំវិញ | 30 សារធាតុគ្រោះថ្នាក់ | | |
| | ការបញ្ចេញជាតិពុល (ពីប្រភពអចល័ត) | 66 ប៉ារ៉ាម៉ែត្រ | | |
| | ការបញ្ចេញជាតិពុល (ពីប្រភពចល័ត) | CO, HC | ដោយរថយន្ត | |
| | សារធាតុក្នុងប្រេងឥន្ធនៈ និងធ្យូងថ្ម | S, Pb | | |
| សំឡេង | សំឡេងរថយន្ត | កម្រិតសំឡេង | កម្រិតអតិបរិមានៃសំឡេងចេញពីរថយន្ត | |
| | សំឡេងនៅតាមតំបន់សាធារណៈ និងលំនៅដ្ឋាន | កម្រិតសំឡេង | កម្រិតអនុញ្ញាតនៅតំបន់ ៤ ប្រភេទ | |
| | កម្រិតសំឡេងនៅរោងចក្រប្រព្រឹត្តិកម្មទឹក | កម្រិតសំឡេង | រយៈពេលអតិបរិមា នៃកម្រិតសំឡេងនីមួយៗ | |
| ទឹក | ស្តង់ដារបញ្ចេញសំណល់ | 52 ប៉ារ៉ាម៉ែត្រ | | អនុក្រិតស្តីពីការត្រួតពិនិត្យការបំពុលទឹក (1999) |
| | គុណភាពទឹក | 5～7 ប៉ារ៉ាម៉ែត្រ ចំពោះតំបន់ទឹកសាធារណៈ | ដើម្បីអភិរក្សជីវចម្រុះ នៅតាមតំបន់ទឹកសាធារណៈ | |
| | គុណភាពទឹក | 25 ប៉ារ៉ាម៉ែត្រ | ដើម្បីការពារសុខភាពសាធារណៈ នៅតាមតំបន់ទឹកសាធារណៈ | |

ប្រភព៖ ក្រុមសិក្សា JICA ដោយយោងតាមអនុក្រិតកម្ពុជា

កម្រិតសំឡេងអនុញ្ញាតអតិបរិមា ទៅតាមតំបន់ មានបង្ហាញក្នុងតារាងខាងក្រោម។ មិនមានស្តង់ដារ ឬបញ្ញត្តិស្តីពីរំញ័រទេ នៅកម្ពុជា។ ស្តង់ដារនេះ ត្រូវគេប្រើដើម្បីត្រួតពិនិត្យកម្រិតសំឡេង នៃប្រភពសំឡេងណាមួយ ដែលបញ្ចេញសំឡេងទៅក្នុងតំបន់សាធារណៈ និងលំនៅដ្ឋាន។ តំបន់គម្រោង ស្ថិតក្នុងប្រភេទទី៣។

## តារាង 1-3-14 កម្រិតសំឡេងអនុញ្ញាតអតិបរិមា dB(A)

| | តំបន់ | អំឡុងពេល | | |
|---|---|---|---|---|
| | | ម៉ោង ៦ ដល់ម៉ោង ១៨ | ម៉ោង ១៨ ដល់ម៉ោង ២២ | ម៉ោង ២២ ដល់ម៉ោង ៦ |
| 1 | តំបន់ស្ងប់ស្ងៀម<br>-មន្ទីរពេទ្យ បណ្ណាល័យ សាលារៀន មត្តេយ្យសាលា | 45 | 40 | 35 |
| 2 | តំបន់លំនៅដ្ឋាន<br>-សណ្ឋាគារ ទីកន្លែងរដ្ឋបាល ភូមិគ្រឹះ ផ្ទះល្វែង | 60 | 50 | 45 |

| | តំបន់ | អំឡុងពេល | | |
|---|---|---|---|---|
| | | ម៉ោង ៦ ដល់ម៉ោង ១៨ | ម៉ោង ១៨ ដល់ម៉ោង ២២ | ម៉ោង ២២ ដល់ ម៉ោង ៦ |
| 3 | តំបន់ពាណិជ្ជកម្ម សេវាកម្ម និងចម្រុះ | 70 | 65 | 50 |
| 4 | ឧស្សាហកម្មធន់ស្រាល លាយចម្រុះនៅក្នុងតំបន់លំនៅដ្ឋាន | 75 | 70 | 50 |

ប្រភព៖ អនុក្រិតស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំឡេង

មន្ទីរបរិស្ថានខេត្តពោធិ៍សាត់ មិនតាមដានស្តង់ដារ និងកម្រិតព្រំដែនដែលបានកំណត់ទេ ដោយសារកង្វះឧបករណ៍ បរិក្ខារ និងសមត្ថភាព។ ស្តង់ដារបញ្ចេញកាកសំណល់ កំណត់ប៉ារ៉ាម៉ែត្រជាច្រើន ប៉ុន្តែខ្វះខាតមន្ទីរពិសោធន៍ ដែលអាចវិភាគប៉ារ៉ាម៉ែត្រទាំងនោះ។ មន្ទីរបរិស្ថានខេត្ត ក៏មិនអាចវិភាគពួកវាបានដែរ។ ហេតុនេះ ក្នុងការអនុវត្តផ្ទាល់ ប៉ារ៉ាម៉ែត្រទាំងនេះ មិនមានការគ្រប់គ្រងឡើយ។ រោងចក្រប្រព្រឹត្តិកម្មទឹក ដែលកំពុងដំណើរការក្នុងប្រទេសកម្ពុជា ជាទូទៅ បញ្ចេញកាកសំណល់សល់ពីដំណើរការប្រព្រឹត្តិកម្ម ចូលក្នុងទន្លេ/ស្ទឹង ដោយផ្ទាល់ ដោយមានកិច្ចសន្យាជាមួយមន្ទីរបរិស្ថាន។

ឧបសម្ពន្ធក្នុងអនុក្រិតស្តីពីការត្រួតពិនិត្យការបំពុលទឹក (១៩៩៩) កំណត់ប្រភពបំពុល ចំនួន ៦៧ ដែលតម្រូវអោយមានការសុំការអនុញ្ញាតពីក្រសួងបរិស្ថាន មុននឹងបញ្ចេញចោល ឬដឹកចេញនូវកាកសំណល់រាវ។ ប្រភពបំពុលប្រភេទ I ត្រូវសុំអនុញ្ញាត បើបរិមាណបញ្ចេញ លើស ១០ ម៣/ថ្ងៃ។ ប្រភេទ II ត្រូវតែសុំអនុញ្ញាត គ្រប់ពេល។ “ការផលិតទឹកសុទ្ធ” ត្រូវចាត់ទុកក្នុងប្រភេទ I ប៉ុន្តែមិនមានបញ្ចេញកាកសំណល់រាវឡើយ។

### 1-3-3-3 នីតិវិធីវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

អនុក្រិតស្តីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (១៩៩៩) មានបង្ហាញបញ្ជីគម្រោង ដែលតម្រូវឲ្យមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ (EIA) ឬហេតុប៉ះពាល់បរិស្ថានដំបូង (IEIA) នៅផ្នែកឧបសម្ពន្ធ។ ប៉ុន្តែ មិនមានការពន្យល់ច្បាស់លាស់ឡើយ ថាតើត្រូវធ្វើ EIA ឬIEIA តែត្រូវសម្រេចដោយក្រសួងបរិស្ថាន។ ករណីគម្រោងដែលមានតម្លៃលើស ២០០ លានដុល្លាសហរដ្ឋអាមេរិក នោះ EIA/IEIA ត្រូវត្រួតពិនិត្យដោយ MOE ផ្ទុយទៅវិញ ត្រូវត្រួតពិនិត្យដោយថ្នាក់ខេត្ត។ គម្រោងនេះ នឹងមានតម្លៃលើស ២០០លានដុល្លាសហរដ្ឋអាមេរិក ដែលនាំឲ្យវាស្ថិតក្រោមទំនួលខុសត្រូវ របស់ក្រសួងបរិស្ថាន។

លំហូរដំណើរការអនុម័តនៃ EIA/IEIA មានបង្ហាញដូចខាងក្រោម។




**រូប 1-3-5 កិច្ចដំណើរការអនុម័ត EIA/IEIA**

ប្រភព៖ អនុក្រិតស្ដីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ១៩៩៩ ដោយមានការប្រជុំផ្សព្វផ្សាយ និងពិភាក្សា

ប្រកាសស្ដីពីការចុះបញ្ជីក្រុមហ៊ុនទីប្រឹក្សាសម្រាប់ការសិក្សា និងរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម មានប្រសិទ្ធភាពនៅខែឧសភា ឆ្នាំ២០១៤ និងតម្រូវឲ្យការសិក្សា និងរបាយការណ៍ ត្រូវធ្វើដោយក្រុមហ៊ុនដែលចុះបញ្ជីត្រឹមត្រូវ។

### 1-3-3-4 ការប្រៀបធៀបបទបញ្ញាកម្ពុជា និងគោលការណ៍ណែនាំ JICA

មិនមានគម្លាតច្រើនទេ រវាងបទបញ្ញាបរិស្ថានកម្ពុជា និងគោលការណ៍ណែនាំ JICA។ តារាងខាងក្រោមបង្ហាញពីគម្លាតរវាងគោលការណ៍ទាំងពីរ ដើម្បីកំណត់គោលការណ៍សិក្សាក្នុងគម្រោង។

**តារាង 1-3-15 គម្លាតរវាងគោលការណ៍បរិស្ថានកម្ពុជា និង JICA**

| លរ | គោលការណ៍ JICA | ច្បាប់ និងបទបញ្ញាបរិស្ថានកម្ពុជា | គម្លាត | គោលការណ៍គម្រោង |
|---|---|---|---|---|
| 1. | ដំណោះស្រាយតាំងទីលំនៅដោយគ្មានការយល់ព្រម និងមានការបាត់បង់ជីវភាពរបរកស៊ី ត្រូវជៀសវាង ពេល | រដ្ឋធម្មនុញ្ញ (1993)<br>មាត្រា 44<br>កម្មសិទ្ធិឯកជនស្របច្បាប់ ស្ថិតនៅក្រោមការគាំពារនៃច្បាប់។ ដែលនឹងដកហូតកម្មសិទ្ធិ អំពីជនណាបាន | ច្បាប់/បទបញ្ញាកម្ពុជា មិនមានចែងអំពីការជៀសវាងការតាំងទីលំនៅដោយគ្មានការយល់ព្រម និងមានការបាត់បង់ | ដំណោះស្រាយតាំងទីលំនៅដោយគ្មានការយល់ព្រម និងមានការបាត់បង់ជីវភាពរបរកស៊ី |

| លរ | គោលការណ៍ JICA | ច្បាប់ និងបទបញ្ញាបរិស្ថានកម្ពុជា | គម្លាត | គោលការណ៍គម្រោង |
|---|---|---|---|---|
| | មានលទ្ធភាពរកជម្រើសដោះស្រាយជំនួសទាំងឡាយ ដែលអាចសម្រេចបាន។ (JICA GL) | នោះ លុះត្រាតែប្រយោជន៍សាធារណៈតម្រូវឲ្យធ្វើ ក្នុងករណីដែលច្បាប់បានបញ្ញត្តិទុក ហើយត្រូវផ្ដល់សំណងជាមុន ដោយសមរម្យ និងយុត្តិធម៌។<br><br>ច្បាប់ភូមិបាល (2001)<br>មាត្រា 4<br>សិទ្ធនៃកម្មសិទ្ធិដែលចែងក្នុងមាត្រ ៤៤ នៃរដ្ឋធម្មនុញ្ញ ១៩៩៣ អនុវត្តទៅលើអចលនវត្ថុទាំងអស់នៃព្រះរាជាណាចក្រកម្ពុជា តាមលក្ខខណ្ឌដែលបានកំណត់ដោយច្បាប់នេះ។<br>មាត្រា 5<br>គ្មានបុគ្គលណាមួយត្រូវបានដកហូតកម្មសិទ្ធិរបស់ខ្លួនបានទេ ប្រសិនបើការដកហូតនេះមិនមែនដើម្បីប្រយោជន៍សាធារណៈ។ ការដកហូតត្រូវធ្វើទៅតាមទម្រង់ និងនីតិវិធីបញ្ញត្តិដោយ ច្បាប់ និងបទបញ្ញា បន្ទាប់ពីបានផ្ដល់សំណងជាមុន ដោយសមរម្យ និងយុត្តិធម៌។ | ជីវភាពរបររកស៊ី ខណៈគោលការណ៍ JICA មានចែង | ត្រូវជៀសវាង ពេលមានលទ្ធភាពរកជម្រើសដោះស្រាយជំនួសទាំងឡាយ ដែលអាចសម្រេចបាន។ |
| 2. | ពេលការផ្លាស់ទីលំនៅមិនអាចជៀសវាងបាន ត្រូវមានវិធានការដ៏ប្រសិទ្ធភាព ដើម្បីកាត់បន្ថយផលប៉ះពាល់ ឲ្យនៅទាបបំផុត និងសងអ្វីដែលបាត់បង់។ (JICA GL) | រដ្ឋធម្មនុញ្ញ (1993)<br>មាត្រា 44<br>(សូមមើលចំនុចទី 1)<br>ច្បាប់ភូមិបាល (2001)<br>មាត្រា 5<br>(សូមមើលចំនុចទី 1) | មិនមានបន្ទាត់ណាមួយក្នុងច្បាប់/បទបញ្ញាកម្ពុជា ដែលចែងអំពីការកាត់បន្ថយផលប៉ះពាល់នៃការផ្លាស់ទីលំនៅ និងបាត់បង់ជីវភាព របររកស៊ី ខណៈគោលការណ៍ JICA មានចែង។ | ពេលការផ្លាស់ទីលំនៅ មិនអាចជៀសវាងបាន ត្រូវមានវិធានការដ៏ប្រសិទ្ធភាព ដើម្បីកាត់បន្ថយផលប៉ះពាល់ ឲ្យនៅទាបបំផុត និងសងអ្វីដែលបាត់បង់។ |
| 3. | ជនណាដែលដាច់ខាតត្រូវតែរើទីតាំងលំនៅដ្ឋានទាំងមិនពេញចិត្ត និងជនណាដែលរងផលវិបាក ឬបាត់បង់មធ្យោបាយ | រដ្ឋធម្មនុញ្ញ (1993)<br>មាត្រា 44<br>(សូមមើលចំនុចទី 1)<br>ច្បាប់ភូមិបាល (2001)<br>មាត្រា 5<br>(សូមមើលចំនុចទី 1) | ទាំងច្បាប់/បទបញ្ញាកម្ពុជា និងគោលការណ៍ JICA មានចែងអំពីសំណង ប៉ុន្តែច្បាប់/បទបញ្ញាកម្ពុជា មិនមានចែងច្បាស់លាស់ទេ អំពីទំហំនៃ | ជនណាដែលដាច់ខាតត្រូវតែរើទីតាំងលំនៅដ្ឋានទាំងមិនពេញចិត្ត និងជនណាដែលរងផលវិបាក ឬ |

| លរ | គោលការណ៍ JICA | ច្បាប់ និងបទបញ្ញាបរិស្ថានកម្ពុជា | គម្លាត | គោលការណ៍គម្រោង |
|---|---|---|---|---|
| | ចិញ្ចឹមជីវិត ត្រូវតែទទួលបានសំណង និងគាំទ្រឲ្យបានគ្រប់គ្រាន់ ដើម្បីធ្វើឲ្យជីវភាពរបស់ពួកគាត់ប្រសើរជាងមុន ឬ យ៉ាងហោចណាស់ ស្តារឲ្យបានដូចដើមមុនមានគម្រោងវិញ នូវស្តង់ដាររស់នៅ ឱកាសរកចំណូល និងកម្រិតផលិតកម្មរបស់ពួកគាត់។ (JICA GL) | ច្បាប់ស្តីពីអស្សាមិករណ៍ (2009)<br>មាត្រា 4<br>**អស្សាមិករណ៍** សំដៅដល់ការដកហូតកម្មសិទ្ធិលើអចលនវត្ថុ ឬសិទ្ធិប្រត្យក្សលើអចលនវត្ថុរបស់រូបវន្ត នីតិបុគ្គលឯកជន និងនីតិបុគ្គលសាធារណៈ រួមមាន ដី សំណង់ និងដំណាំដាំដុះ សម្រាប់បម្រើការស្ថាបនា ស្តារ និងពង្រីកហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈដែលបម្រើប្រយោជន៍សាធារណៈ និងផលប្រយោជន៍ជាតិ ព្រមទាំងផ្តល់នូវសំណងជាមុនដោយសមរម្យ និងយុត្តិធម៌។<br>មាត្រា 22<br>ប្រាក់សំណងដែលត្រូវផ្តល់ឲ្យទៅម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិ ត្រូវគិតតាមថ្លៃទីផ្សារ ឬថ្លៃជំនួសនៅកាលបរិច្ឆេទនៃការចេញសេចក្តីប្រកាសស្តីពីគម្រោងអស្សាមិករណ៍។ ថ្លៃទីផ្សារ ឬថ្លៃជំនួស ត្រូវកំណត់ដោយគណៈកម្មការ ឬភ្នាក់ងារឯករាជ្យមួយតាមការជ្រើសរើសរបស់គណៈកម្មាធិការអស្សាមិករណ៍។ | សំណង។ ដូចគ្នានេះដែរ ដូចបានរៀបរាប់ក្នុងចំនុចទី ២ គោលការណ៍ JICA មានចែងអំពីសំណងដល់ការបាត់បង់មធ្យោបាយចិញ្ចឹមជីវិត ខណៈច្បាប់/បទបញ្ញាកម្ពុជា ចែងអំពីការសងអចលនវត្ថុរបស់ម្ចាស់កម្មសិទ្ធិ ឬនីតិបុគ្គល តែប៉ុណ្ណោះ។ លើសពីនេះទៀត គោលការណ៍ JICA ចែងអំពីកម្មវត្ថុនៃសំណង គឺជនដែលត្រូវផ្លាស់ទីលំនៅអាចមានស្តង់ដាររស់នៅកាន់តែប្រសើរជាងមុន ឬ យ៉ាងហោចណាស់ ស្តារអោយបានដូចមុន។ | បាត់បង់មធ្យោបាយចិញ្ចឹមជីវិត ត្រូវតែទទួលបានសំណង និងគាំទ្រឲ្យបានគ្រប់គ្រាន់ ដើម្បីធ្វើឲ្យជីវភាពរបស់ពួកគាត់ប្រសើរជាងមុន ឬ យ៉ាងហោចណាស់ ស្តារឲ្យបានដូចដើមមុនមានគម្រោងវិញ នូវស្តង់ដាររស់នៅ ឱកាសរកចំណូល និងកម្រិតផលិតកម្មរបស់ពួកគាត់។ |
| 4. | សំណង ត្រូវតែជាតម្លៃ full replacement cost តាមដែលអាចសងបាន។ (JICA GL) | ច្បាប់ស្តីពីអស្សាមិករណ៍ (2009)<br>មាត្រា 23<br>ម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិ មានសិទ្ធិទទួលបាននូវសំណងលើការខូចខាតអចលនវត្ថុជាក់ស្តែង ដែលមានចាប់ពីថ្ងៃចេញសេចក្តីប្រកាសស្តីពីគម្រោងអស្សាមិករណ៍ ដែលជាកាលបរិច្ឆេទចុងក្រោយសម្រាប់មានសិទ្ធិទទួលបាននូវសំណងសមរម្យ និងយុត្តិធម៌។ | សំណងដែលមានចែងក្នុងគោលការណ៍ JICA រួមបញ្ចូលតម្លៃចាំបាច់សម្រាប់ស្តារមធ្យោបាយចិញ្ចឹមជីវិតអោយដូចមុនមានគម្រោង ខណៈច្បាប់/បទបញ្ញា មានចែងតែ "ការខូចខាតជាក់ស្តែង (actual damage)" ដោយគ្មានព័ត៌មានលំអិត។ | សំណង ត្រូវតែជាតម្លៃ full replacement cost តាមដែលអាចសងបាន។ |
| 5. | សំណង និងការគាំពារផ្សេងៗ ត្រូវធ្វើមុនពេល | រដ្ឋធម្មនុញ្ញ (1993)<br>មាត្រា 44 | ទាំងច្បាប់/បទបញ្ញាកម្ពុជា ចែងអំពីសំណង | សំណង និងការគាំពារផ្សេងៗ ត្រូវ |

| លរ | គោលការណ៍ JICA | ច្បាប់ និងបទបញ្ញាបរិស្ថានកម្ពុជា | គម្លាត | គោលការណ៍គម្រោង |
|---|---|---|---|---|
| | ផ្លាស់ទីលំនៅ។ (JICA GL) | (សូមមើលចំនុចទី 1)<br>ច្បាប់ភូមិបាល (2001)<br>មាត្រា 5<br>(សូមមើលចំនុចទី 1)<br>ច្បាប់ស្តីពីអស្សាមិករណ៍ (2009)<br>មាត្រា 19<br>ការដកហូតកម្មសិទ្ធិលើអចលនវត្ថុ និង សិទ្ធិប្រត្យក្សលើអចលនវត្ថុ អាចធ្វើទៅបាន លុះត្រាតែគណៈកម្មាធិការអស្សាមិករណ៍ បានផ្តល់សំណងឲ្យម្ចាស់អចលនវត្ថុ និង/ឬម្ចាស់សិទ្ធិជាមុន ដោយសមរម្យ និងយុត្តិធម៌ តាមគោលការណ៍ និងនីតិវិធីនៃការទូទាត់សំណង ដូចមានចែងក្នុងផ្នែកទី ៣ ជំពូកទី ៤ នៃច្បាប់នេះ។ | មុនការផ្លាស់ទីលំនៅ ខណៈច្បាប់/បទបញ្ញាកម្ពុជា មិនមានចែងអំពី “ការគាំពារផ្សេងៗទៀត” ឡើយ។ | ធ្វើមុនពេលផ្លាស់ទីលំនៅ។ |
| 6. | ចំពោះគម្រោង ដែលមានការផ្លាស់ទីលំនៅដោយមិនស្ម័គ្រចិត្តក្នុងចំនួនច្រើន នោះ ផែនការផ្លាស់ទីលំនៅ (RAP) ត្រូវរៀបចំ និងផ្សព្វផ្សាយជាសាធារណៈ។ (JICA GL) | គ្មានបទបញ្ញា ឬច្បាប់ដែលអាចធៀបគ្នា។ | ច្បាប់/បទបញ្ញាកម្ពុជា មិនមានចែងអំពីការរៀបចំផែនការផ្លាស់ទីលំនៅ (RAP) ទេ។ | ចំពោះគម្រោង ដែល មានការផ្លាស់ទីលំនៅដោយមិនស្ម័គ្រចិត្តក្នុងចំនួនច្រើន នោះ ផែនការផ្លាស់ទីលំនៅ (RAP) ត្រូវរៀបចំ។ |
| 7. | ក្នុងការរៀបចំផែនការផ្លាស់ទីលំនៅ ត្រូវមានការប្រឹក្សាយោបល់ជាមួយអ្នកទទួលផលប៉ះពាល់ និងសហគមន៍របស់ពួកគេ ដោយផ្អែកលើព័ត៌មានគ្រប់ជ្រុងជ្រោយផ្តល់ដល់ពួកគេជាមុន។ (JICA GL) | ច្បាប់ស្តីពីអស្សាមិករណ៍ (2009)<br>មាត្រា 16<br>ក្នុងការធ្វើការអង្កេតនេះ គណៈកម្មាធិការអស្សាមិករណ៍ត្រូវរៀបចំចាត់ចែងធ្វើការពិគ្រោះយោបល់ជាសាធារណៈ នៅក្នុងកម្រិតអាជ្ញាធរ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ និង តំណាងភូមិ ឬ សហគមន៍ដែលរងនូវអស្សាមិករណ៍ ដើម្បីផ្តល់ព័ត៌មាន ជាក់លាក់ ច្បាស់លាស់ និង | គោលការណ៍ទាំងពីរ ចែងអំពីការប្រឹក្សាយោបល់ជាសាធារណៈ ដោយមានផ្តល់ព័ត៌មានគ្រប់ជ្រុងជ្រោយ ខណៈច្បាប់/បទបញ្ញាកម្ពុជា មិនមានចែងអំពីការរៀបចំផែនការផ្លាស់ទីលំនៅ (RAP) ទេ។ | ក្នុងការរៀបចំ RAP ការប្រឹក្សាយោបល់ជាសាធារណៈ ត្រូវរៀបចំឡើង ដោយមានការគិតគូរអំពីភាសា និងនីតិវិធី។ |

| លរ | គោលការណ៍ JICA | ច្បាប់ និងបទបញ្ញាបរិស្ថានកម្ពុជា | គម្លាត | គោលការណ៍គម្រោង |
|---|---|---|---|---|
| | | ទទួលបាននូវមតិយោបល់ពីគ្រប់ភាគីពាក់ព័ន្ធអំពីសំណើនៃគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណ:។ | | |
| 8. | ពេលរៀបចំការប្រឹក្សាយោបល់ជាសាធារណ: ការពន្យល់ ត្រូវធ្វើឡើងក្នុងទម្រង់ បែបបទ និងភាសា ដែលងាយយល់ចំពោះអ្នកដែលរងផលប៉ះពាល់។ (JICA GL) | ច្បាប់ស្តីពីអស្សាមិករណ៍ (2009)<br>មាត្រា 16 (មើលចំនុច 7)<br>សម្គាល់៖ គ្មានសេចក្តីពិពណ៍នាអំពីរបៀប និងភាសាក្នុងការពន្យល់ទេ។ | គោលការណ៍ទាំងពីរ ចែងអំពី ការប្រឹក្សាយោបល់ជាសាធារណ: ខណ: គោលការណ៍ JICA មានបញ្ជាក់លំអិត អំពីបែបបទ ជាពិសេសលទ្ធភាពរៀបចំការប្រឹក្សាយោបល់។ | ការជួបជុំប្រឹក្សាយោបល់ ត្រូវធ្វើឡើង ដោយប្រើភាសា និងមាននីតិវិធី ដែលងាយយល់ចំពោះអ្នករងផលប៉ះពាល់។ |
| 9. | ត្រូវលើកកម្ពស់ការចូលរួមដ៏សមរម្យពីសំណាក់អ្នករងផលប៉ះពាល់ ទាំងក្នុងដំណាក់កាលធ្វើផែនការ ដំណាក់កាលអនុវត្ត និងដំណាក់កាលតាមដានផែនការផ្លាស់ទីលំនៅ។ (JICA GL) | ច្បាប់ស្តីពីអស្សាមិករណ៍ (2009)<br>មាត្រា 16<br>ក្នុងការធ្វើការអង្កេតនេះ គណ:កម្មាធិការអស្សាមិករណ៍ត្រូវរៀបចំចាត់ចែងធ្វើការពិគ្រោះយោបល់ជាសាធារណ: នៅក្នុងកម្រិតអាជ្ញាធរ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ និង តំណាងភូមិ ឬ សហគមន៍ដែលរងនូវអស្សាមិករណ៍។<br><br>អនុក្រិតស្តីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (1999)<br>មាត្រា 1<br>បំផុសឲ្យមានការចូលរួមពីសាធារណជន ក្នុងកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថា ព្រមទាំងទទួលយកមតិ យោបល់ មកធ្វើការពិចារណា ក្នុងកិច្ចដំណើរការអនុម័តគម្រោង។ | ច្បាប់ស្តីពីអស្សាមិករណ៍ ចែងអំពីការចូលរួមរបស់អ្នករងផលប៉ះពាល់ ក្នុងការប្រឹក្សាយោបល់ជាសាធារណ: ខណ: គោលការណ៍ JICA លើកកម្ពស់ការចូលរួមរបស់អ្នករងផលប៉ះពាល់ នៅគ្រប់ដំណាក់កាលនៃគម្រោង។ | ត្រូវលើកកម្ពស់ការចូលរួមដ៏សមរម្យពីសំណាក់អ្នករងផលប៉ះពាល់ ទាំងក្នុងដំណាក់កាលធ្វើផែនការ ដំណាក់កាលអនុវត្ត និងដំណាក់កាលតាមដានផែនការផ្លាស់ទីលំនៅ (RAP)។ |
| 10. | យន្តការដែលអាចឲ្យអ្នករងផលប៉ះពាល់ និងសហគមន៍ពួកគាត់អាចដាក់បណ្តឹងតវ៉ាដ៏សមរម្យ ត្រូវតែរៀបចំ | ច្បាប់ស្តីពីអស្សាមិករណ៍ (2009)<br>មាត្រា 14<br>គណ:កម្មាធិការដោះស្រាយបណ្តឹងតវ៉ា ត្រូវតែបង្កើតឡើង និងដឹកនាំដោយតំណាងក្រសួងរៀបចំដែនដី | គោលការណ៍ទាំងពីរ ចែងអំពីការរៀបចំយន្តការដោះស្រាយបណ្តឹងតវ៉ា។ ច្បាប់ស្តីពីអស្សាមិករណ៍មិនគ្រាន់ក្នុងពេលអនុវត្ត | យន្តការដែលអាចឲ្យអ្នករងផលប៉ះពាល់ និងសហគមន៍ពួកគាត់ អាចដាក់ |

| លរ | គោលការណ៍ JICA | ច្បាប់ និងបទបញ្ញាបរិស្ថានកម្ពុជា | គម្លាត | គោលការណ៍គម្រោង |
|---|---|---|---|---|
| | ឡើង។ (JICA GL) | នគរូបនីយកម្ម និងសំណង់ និងមានតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធចូលរួម។<br>ការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ា ត្រូវកំណត់ដោយអនុក្រិតដោយឡែក។ | ខណៈគោលការណ៍ JICA បញ្ជាក់យ៉ាងលំអិត ជាពិសេស អំពីលទ្ធភាពរៀបចំការប្រឹក្សាយោបល់។ | បណ្តឹងតវ៉ាជំ សមរម្យ ត្រូវតែរៀបចំឡើង។ |
| 11. | ត្រូវកំណត់អត្តសញ្ញាណ និងកត់ត្រា អ្នករងផលប៉ះពាល់ ឲ្យបានលឿនជាទីបំផុត ដើម្បីបញ្ជាក់សិទ្ធ (eligibility) របស់ពួកគាត់ តាមរយៈការអង្កេតជាមូលដ្ឋាន (baseline survey) (តាមរយៈជំរឿនផងដែរ ដែលប្រើជា កាលបរិច្ឆេទគោលនៃសិទ្ធ បញ្ជីសារពើភ័ន្ធទ្រព្យ និងការអង្កេតសេដ្ឋកិច្ចសង្គម) ជាពិសេសនៅដំណាក់កាលកំណត់អត្តសញ្ញាណកម្មគម្រោង ដើម្បីទប់ស្កាត់អ្នកឆ្លៀតឱកាសចូលមកតាំងទីលំនៅដើម្បីទទួលបានផលប្រយោជន៍។ (WB OP4.12 Para.6) | ច្បាប់ស្តីពីអស្សាមិករណ៍ (2009)<br>មាត្រា 16<br>មុននឹងធ្វើសំណើស្តីពីគម្រោងអស្សាមិករណ៍ គណៈកម្មាធិកាអស្សាមិករណ៍ត្រូវធ្វើការអង្កេតជាសាធារណៈ ដោយត្រូវកត់ត្រាភិនភាគឲ្យបានលម្អិតចំពោះរាល់សិទ្ធរបស់ម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធ លើអចលនវត្ថុ និងទ្រព្យសម្បត្តិផ្សេងៗទៀតដែលមានជាប់ពាក់ព័ន្ធនឹងការផ្តល់សំណង ព្រមទាំងត្រូវកត់ត្រានូវរាល់បញ្ហាពាក់ព័ន្ធ។ | គោលការណ៍ទាំងពីរចែងអំពីការរៀបចំការអង្កេតយ៉ាងជាក់លាក់។<br>ច្បាប់អស្សាមិករណ៍ ផ្តោតទៅលើសិទ្ធរបស់ម្ចាស់អចលនវត្ថុ និងម្ចាស់សិទ្ធលើអចលនវត្ថុ ខណៈគោលការណ៍ JICA នៅចំនុច<br>OP4.12 ដែលគិតគូរទាំងអ្នករងផលប៉ះពាល់ដែលមានសិទ្ធស្របច្បាប់ និងគ្មានសិទ្ធស្របច្បាប់។ | ត្រូវកំណត់ អត្តសញ្ញាណ និង កត់ត្រា អ្នករងផលប៉ះពាល់ ឲ្យបានលឿនជាទីបំផុត ដើម្បីបញ្ជាក់សិទ្ធ (eligibility) របស់ពួកគាត់ តាមរយៈការអង្កេតជាមូលដ្ឋាន (baseline survey)។ |
| 12. | សិទ្ធទទួលបានផលប្រយោជន៍មាន (Eligibility of benefits)៖ អ្នករងផលប៉ះពាល់ដែលមានសិទ្ធស្របច្បាប់លើអចលនវត្ថុ (រួមទាំងសិទ្ធិតាមបែបទម្លាប់ | ច្បាប់ស្តីពីអស្សាមិករណ៍ (2009)<br>មាត្រា 4<br>ម្ចាស់អចលនវត្ថុ និង/ឬម្ចាស់សិទ្ធិ សំដៅដល់រូបវន្តបុគ្គល នីតិបុគ្គលឯកជន និងនីតិបុគ្គលសាធារណៈ រួមមាន កម្មសិទ្ធិករ ភោគី និងអ្នកមានសិទ្ធិទាំងឡាយនៅលើទីតាំងដី | ច្បាប់ស្តីពីអស្សាមិករណ៍ចែងថា "ម្ចាស់អចលនវត្ថុ និងឬម្ចាស់សិទ្ធិ ជាអ្នកមានសិទ្ធិទទួលបានសំណង ខណៈគោលការណ៍ JICA គិតទាំងអ្នកគ្មានសិទ្ធិស្របច្បាប់ ថាមាន | សិទ្ធិទទួលសំណងមិនត្រឹមតែអ្នករងផលប៉ះពាល់ដែលមានសិទ្ធិស្របច្បាប់ប៉ុណ្ណោះទេ តែអ្នករងផលប៉ះពាល់ដែលគ្មានសិទ្ធិស្រប |

| លរ | គោលការណ៍ JICA | ច្បាប់ និងបទបញ្ញាបរិស្ថានកម្ពុជា | គម្លាត | គោលការណ៍គម្រោង |
|---|---|---|---|---|
| | និងប្រពៃណី ដែលស្ថិតក្រោមច្បាប់)។ អ្នករងផលប៉ះពាល់ដែលគ្មានសិទ្ធស្របច្បាប់ នៅខណៈមានជំរឿន ប៉ុន្តែ មានការអះអាងទាមទារអចលនវត្ថុ ឬទ្រព្យនេះ។ អ្នករងផលប៉ះពាល់ដែលមិនមានសិទ្ធស្របច្បាប់លើអចលនវត្ថុដែលគាត់កំពុងកាន់កាប់។ (WB OP4.12 Para.15) | ដែលជាអ្នកទទួលរងនូវផលប៉ះពាល់ដោយសារគម្រោងអស្សាមិករណ៍។<br><br>ច្បាប់ភូមិបាល (2001)<br>មាត្រា 18<br>ត្រូវទុកជាមោឃៈ និងគ្មានអានុភាព ហើយមិនអាចត្រូវបានធ្វើនិយកកម្ម ទោះតាមរូបភាពណាក់ដោយនូវ៖<br>- រាល់ការចូលកាន់កាប់ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណ: និង រាល់ការបំប្លែងការកាន់កាប់ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋទៅជាសិទ្ធិកម្មសិទ្ធិ ទោះបីការកាន់កាប់ និង ការបំប្លែងនេះកើតមាននៅពេលណាក់ដោយ ដែលមិនស្របតាមលិខិតបទដ្ឋានគតិយុត្តិ និងនីតិវិធីដែលបានកំណត់កន្លងមក<br>- រាល់ការបំប្លែងទៅជាសិទ្ធិកម្មសិទ្ធិនៃដីសម្បទាន ទោះជាការបំប្លែងនេះកើតឡើងមុន ពេលច្បាប់នេះចូល ជាធរមានក៍ដោយ លើកលែងតែសម្បទានដែលឆ្លើយតមទៅ នឹងប្រយោជន៍សង្គម<br>- រាល់សម្បទានមិនស្របនឹងបញ្ញត្តិទាំងឡាយនៃជំពូកទី ៥<br>- រាល់ការចូលកាន់កាប់ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ទោះជាតាមរូបភាពណាក់ដោយដែលបានកើតឡើងក្រោយច្បាប់នេះចូលជាធរមាន។ | សិទ្ធិទទួលសំណង។ | ច្បាប់ផងដែរ។ |
| 13. | សំណងអាទិភាព គួរប្រើយុទ្ធសាស្ត្រ land-based resettlement strategies ចំពោះអ្នកត្រូវផ្លាស់ទីលំនៅ ដែលជីវភាពពួកគាត់ពឹងផ្អែកលើដី | គ្មានបទបញ្ញា ឬច្បាប់ដែលអាចធៀបគ្នា។ | ច្បាប់/បទបញ្ញាកម្ពុជាមិនមានចែងអំពីយុទ្ធសាស្ត្រ land-based resettlement strategies ឡើយ។ | សំណងអាទិភាព គួរប្រើយុទ្ធសាស្ត្រ land-based resettlement strategies ចំពោះអ្នកត្រូវផ្លាស់ |

| លរ | គោលការណ៍ JICA | ច្បាប់ និងបទបញ្ញាបរិស្ថានកម្ពុជា | គម្លាត | គោលការណ៍គម្រោង |
|---|---|---|---|---|
| | (land based livelihoods)។ (WB OP4.12 Para.11) | | | ទីលំនៅ ដែលជីវភាពពួកគាត់ពឹងផ្អែកលើដី (land based livelihoods)។ |
| 14. | ផ្តល់ការគាំពារនៅដំណាក់កាលអន្តរកាល (រវាងពេលផ្លាស់ទីលំនៅ និងពេលស្តារបានដូចដើមវិញនូវស្ថានភាពរស់នៅ)។ (WB OP4.12 Para.6) | គ្មានបទបញ្ញា ឬច្បាប់ដែលអាចធៀបគ្នា។ | ច្បាប់/បទបញ្ញាកម្ពុជាមិនមានចែងអំពីការគាំពារនៅដំណាក់កាលអន្តរកាលទេ។ | អ្នករងផលប៉ះពាល់នឹងទទួលបានការគាំពារនៅដំណាក់កាលអន្តរកាល។ |
| 15. | ត្រូវមានការយកចិត្តទុកដាក់ជាពិសេស ដល់ក្រុមងាយរងគ្រោះទាំងឡាយ ក្នុងចំណោមអ្នកដែលត្រូវផ្លាស់ទីលំនៅទាំងអស់ ពិសេសអ្នកដែលមានជីវភាពក្រោមបន្ទាត់ក្រីក្រ អ្នកគ្មានដីធ្លី មនុស្សចាស់ជរា ស្ត្រី និងកុមារ ជនជាតិភាគតិច ។ល។ (WB OP4.12 Para.8) | គ្មានបទបញ្ញា ឬច្បាប់ដែលអាចធៀបគ្នា។ | ច្បាប់/បទបញ្ញាកម្ពុជាមិនមានចែងអំពីការគាំពារ ឬការយកចិត្តទុកដាក់ ដល់ក្រុមដែលងាយរងគ្រោះទេ។ | ត្រូវមានការយកចិត្តទុកដាក់ដល់ជនជាតិភាគតិច និងអ្នកក្រខ្សត់។ |
| 16. | ចំពោះគម្រោងដែលពាក់ព័ន្ធនឹងការទិញដី ឬការផ្លាស់ទីលំនៅរបស់មនុស្សតិចជាង ២០០ នាក់ នោះត្រូវរៀបចំផែនការសកម្មភាពផ្លាស់ទីលំនៅសង្ខេប (ARAP)។ (WB OP4.12 Para.25) | គ្មានបទបញ្ញា ឬច្បាប់ដែលអាចធៀបគ្នា។ | ច្បាប់/បទបញ្ញាកម្ពុជាមិនមានចែងអំពីការរៀបចំផែនការ RAP ឬ ARAP ទេ។ | ត្រូវរៀបចំផែនការ ARAP ចំពោះការផ្លាស់ទីលំនៅដែលពាក់ព័ន្ធនឹងការទិញដី និងដោយមិនស្ម័គ្រចិត្ត ក្នុងទ្រង់ទ្រាយតូច។ |

ប្រភព៖ ក្រុមសិក្សា JICA ដោយយោងច្បាប់/បទបញ្ញាកម្ពុជា